# សំណួរ ~ ចម្លើយ
## ជំនួយស្មារតី

# ចំណេះដឹងវិជ្ជាពលរដ្ឋ ក្នុងអំឡុងពេលបោះឆ្នោត និងក្រោយពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ



ខែ ឧសភា ២០០៨

# មាតិកា


ល.រ ទំព័រ

១ . លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ........................................ ១

២ . ការបោះឆ្នោត និងសិទ្ធិអ្នកបោះឆ្នោត ........................................ ១០

៣ . ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

សិទ្ធិ និងនីតិវិធី ........................................ ១៨

. យុទ្ធនាការឃោសនាបោះឆ្នោត ........................................ ២៤

. នៅថ្ងៃបោះឆ្នោត ........................................ ២៨

. ការរាប់សន្លឹកឆ្នោត ........................................ ៣៧

. ទោសប្បញ្ញត្តិ និងបណ្តឹង ........................................ ៣៨

៤ . យេនឌ័រ និងកូតាជាតំណាងអ្នកបោះឆ្នោត ........................................ ៤៣

៥ . យុវជន និងនយោបាយ ........................................ ៥១

# លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស




## ១. អ្វីទៅដែលហៅថាលទ្ធិប្រជាធិបតេយ្យ ?

**លទ្ធិ :** របប ការនិយម ការយល់ឃើញ

**ប្រជា :** ប្រជាជន ប្រជាពលរដ្ឋ

**អធិបតី ឬ អធិបតេយ្យ :** ធំ សម្បើម ក្រៃលែង

លទ្ធិប្រជាធិបតេយ្យជាទម្រង់នៃការដឹកនាំប្រទេសដែលអំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋពិតប្រាកដ ។ អំណាចកំពូលក្នុងរដ្ឋាភិបាល ស្ថិតក្នុងកណ្ដាប់ដៃប្រជាពលរដ្ឋ ប្រើប្រាស់ដោយប្រជាពលរដ្ឋផ្ទាល់ ឬ/និង ដោយអ្នកតំណាងប្រជាពលរដ្ឋដែលជ្រើសរើសដោយប្រជាពលរដ្ឋតាមរយៈការបោះឆ្នោត។ អ្វីៗដែលរដ្ឋាភិបាល និងតំណាងប្រជាពលរដ្ឋធ្វើ គឺត្រូវស្របតាមឆន្ទៈរបស់ប្រជាពលរដ្ឋ និងផ្ដល់ផលប្រយោជន៍ទៅប្រជាពលរដ្ឋ។ នៅក្នុងលទ្ធិប្រជាធិបតេយ្យប្រជាពលរដ្ឋមានអំណាច មានសិទ្ធិសេរីភាពច្រើនបំផុត ។

ជាទស្សនៈទូទៅរដ្ឋាភិបាល ប្រជាធិបតេយ្យជារដ្ឋាភិបាលដែលកើតឡើងដោយប្រជាពលរដ្ឋ ជារបស់ប្រជាពលរដ្ឋ និងដើម្បីប្រជាពលរដ្ឋ ។

## ២. ប្រជាធិបតេយ្យត្រូវបានគេចែកចេញជាប៉ុន្មានប្រភេទ ?

ប្រជាធិបតេយ្យ បែងចែកជាពីរប្រភេទ គឺប្រជាធិបតេយ្យដោយផ្ទាល់ និង ប្រជាធិបតេយ្យតាមរយៈតំណាង ។

ក) *ប្រជាធិបតេយ្យដោយផ្ទាល់* : គឺប្រជាពលរដ្ឋគ្រប់រូប អាចចូលរួមក្នុងការអនុម័តសេចក្ដីសំរេចដោយផ្ទាល់ ឬអនុវត្តសកម្មភាពការងារជាសាធារណៈដោយប្រជាពលរដ្ឋខ្លួនឯងគឺមិនតាមរយៈមន្ត្រី ដែលខ្លួនជ្រើសតាំង ឬតែងតាំងឡើយ ។

**ឧទាហរណ៍** : ការធ្វើប្រជាមតិក្នុងការសំរេចអនុមត័ច្បាប់ ឬគោលការណ៍អ្វីមួយ ។

ខ) *ប្រជាធិបតេយ្យតាមរយៈតំណាង ឬ ប្រជាធិបតេយ្យដោយប្រយោល*: តាមរយៈការបោះឆ្នោតជ្រើសរើសអ្នកតំណាងដោយប្រជាពលរដ្ឋ ដើម្បីឱ្យមកធ្វើសេចក្ដីសំរេចចិត្តផ្នែកនយោបាយ រៀបចំច្បាប់ និងគោលនយោបាយ សំរាប់ផលប្រយោជន៏សាធារណៈ ។ ប្រជាធិបតេយ្យតាមរយៈតំណាងនេះ ត្រូវបានគេយកមកអនុវត្តដោយសារតែភាពធំធេង និងសាំញ៉ាំរបស់សង្គមនៅសម័យបច្ចុប្បន្ន ។

**ឧទាហរណ៍** : ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ។

## ៣. តើធាតុសំខាន់ៗនៅក្នុងលទ្ធិប្រជាធិបតេយ្យពិតប្រាកដមានអ្វីខ្លះ?

ធាតុសំខាន់ៗរបស់លទ្ធិប្រជាធិបតេយ្យ :

- **ការគោរសិទ្ធិមនុស្សជាមូលដ្ឋាន** : សិទ្ធិពលរដ្ឋ, សិទ្ធិនយោបាយ, សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គម-វប្បធមិ ។
- **សេរីភាពបញ្ចេញមតិ សារព័តិមាន និងការប្រជុំ** : ប្រជាពលរដ្ឋមានសិទ្ធិបង្កើតសារព័តិមាន, វិទ្យុ, ទូរទស្សន៍ មានសិទ្ធិទទួល និងផ្សព្វផ្សាយព័តិមាន សេរីភាពបង្កើតគណបក្សនយោបាយអង្គការសង្គម គណៈវិជ្ជាជីវៈ សេរីភាពក្នុងការប្រជុំ និងសេរីភាពធ្វើបាតុកម្ម និង កូដកម្មដោយសន្តិវិធី ។
- **ការបោះឆ្នោត** ដោយសេរី យុត្តិធមិ សម្ងាត់ និង ទៀងទាត់
- **ការផ្ទេរអំណាច** : អ្នកចាញ់ផ្ទេរអំណាចទៅឱ្យអ្នកឈ្នះដោយសន្តិវិធី

- ♦ **ពហុនិយម និងការអធ្យាស្រ័យ** ៖ ការសំរេចអ្វីមួយយកតាមសំលេងភាគច្រើន និងគោរព ពិចារណាលើមតិភាគតិច ។
- ♦ **ការបែងចែកអំណាច** ( អំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ អំណាចតុលាការ)៖ អំណាចត្រូវបែងចែកដាច់ៗពីគ្នា ដោយមិនអនុញ្ញាតឱ្យបុគ្គល ឬស្ថាប័នណាមួយ មានអំណាច ហួសហេតុ គ្មានការត្រួតពិនិត្យនោះឡើយ ។ ការបែងចែកអំណាច សំដៅជាពិសេសដល់ការធានានូវឯករាជ្យភាពរបស់តុលាការ ។

  - **អំណាចនីតិបញ្ញត្តិ** (រដ្ឋសភា និងព្រឹទ្ធសភា)៖ មានមុខនាទីតាក់តែងច្បាប់ អនុម័តច្បាប់ និងគោលនយោបាយផ្សេងៗ និងត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាល ។

  - **អំណាចនីតិប្រតិបត្តិ** (រដ្ឋាភិបាល)៖ មានមុខនាទីអនុវត្តច្បាប់ ធ្វើសេចក្តីព្រាងច្បាប់ ដឹកនាំការងារប្រចាំថ្ងៃរបស់រដ្ឋាភិបាល និងអភិវឌ្ឍន៍ប្រទេសឱ្យមានការរីកចំរើន ។

  - **អំណាចតុលាការ** ៖ មានមុខនាទីធានាការគោរពច្បាប់ ផ្តល់យុត្តិធម៌សង្គម និងផ្តន្ទាទោសជនណាដែលរំលោភច្បាប់ ។

  ការបែងចែកអំណាច ជាគោលនយោបាយមួយសំរាប់វាស់ពីក៏រិតការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងការត្រួតពិនិត្យតុល្យភាពនៃអំណាចទាំងការអនុមត័ និងអនុវត្តច្បាប់ ។
- ♦ **ការចូលរួមរបស់ប្រជាពលរដ្ឋ** ៖ ការសំរេចចិត្តនានា រួមទាំងការបង្កើតច្បាប់ត្រូវមានការចូលរួមយោបល់ពីប្រជាពលរដ្ឋ និងយកទៅផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានយល់ដឹង និងអនុវត្ត ។
- ♦ **នីតិរដ្ឋ** ៖ រដ្ឋគោរពច្បាប់ រដ្ឋដែលយកច្បាប់ជាធំ ឬដែលមានរដ្ឋាភិបាលគ្រប់គ្រងតាមអំណាចនៃច្បាប់ គឺមិនមែនតាមអំណាចបុគ្គល ឬក្រុមបុគ្គលណាមួយឡើយ ។ មន្ត្រីនគរបាល និងតុលាការត្រូវមានវិជ្ជាជីវៈ ច្បាប់ពិតប្រាកដទាំងរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋត្រូវចូលរួមគោរពច្បាប់ទាំងអស់គ្នាដោយស្មើភាព ។

## ៤. របបគ្រប់គ្រងរដ្ឋមានប៉ុន្មានយ៉ាង ?

របបផ្តាច់ការ របបកុម្មុយនីស និងរបបហ្វាស៊ីស មិនមែនជារបបប្រជាធិបតេយ្យទេ។

**របបគ្រប់គ្រងមាន ៣ យ៉ាង គឺ :**

- **របបប្រធានាធិបតីនិយម :** ប្រធានាធិបតីត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋ, មិនមាននាយករដ្ឋមន្ត្រីទេ ដូចជា សហរដ្ឋអាមេរិក, ហ្វីលីពីន, ឥណ្ឌូណេស៊ី ... ( អំណាចសភា និងរដ្ឋាភិបាលដាច់ពីគ្នា) ។
- **របបសភានិយម :** រដ្ឋសភាត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជាពលរដ្ឋ ហើយរដ្ឋសភាបោះឆ្នោតទុកចិត្តនាយករដ្ឋមន្ត្រី និងសមាជិករដ្ឋាភិបាលទាំងមូល ដូចជាកម្ពុជា ជប៉ុន ថៃ អង់គ្លេស...។ មានតែនាយករដ្ឋមន្ត្រី, មិនមានប្រធានាធិបតីទេ (អំណាចសភា និងរដ្ឋាភិបាលមានតុល្យភាពជាមួយគ្នា) ។
- **របបចំរុះ :** ប្រធានាធិបតី ត្រូវបានបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ ហើយប្រធានាធិបតី តែងតាំងនាយករដ្ឋមន្ត្រី ដូចជា បារាំង និងរុស្ស៊ី ( មានប្រធានាធិបតីផង និងនាយករដ្ឋមន្ត្រីផង ) ។

## ៥. សិទ្ធិប្រជាពលរដ្ឋក្នុងលទ្ធិប្រជាធិបតេយ្យ

ក្នុងរបបលទ្ធិប្រជាធិបតេយ្យសេរី ប្រជាពលរដ្ឋមានសិទ្ធិបង្កើតមធ្យោបាយផ្សព្វផ្សាយពតិមាន និងមតិយោបល់ដោយខ្លួនឯងបាន ដូចជា សារព័ត៌មាន វិទ្យុទូរទស្សន៍ តាមសេចក្តីអនុញ្ញាតពីក្រសួងពតិមាន ទោះក្នុងកិច្ចការនយោបាយក្តី ប្រជាពលរដ្ឋមានសិទ្ធិបង្កើតសហគមន៍ផ្សេងៗ ដោយរួមទាំងគណបក្សនយោបាយផង ដើម្បីផ្សព្វផ្សាយគំនិតរបស់គេស្តីពីការគ្រប់គ្រងប្រទេស។ ពលរដ្ឋមានសិទ្ធិជាចាំបាច់ក្នុងការបោះឆ្នោតព្រោះពួកគេមិនអាចទៅគ្រប់គ្រងរដ្ឋទាំងអស់គ្នាបានទេ គេត្រូវតែជ្រើសរើសតំណាងតាមមតិភាគច្រើនឱ្យធ្វើការជំនួសគេ ដើម្បីចៀសវាងសង្គ្រាមបង្ហូរឈាម ពិសេសបោះឆ្នោតធ្វើឱ្យមានការផ្លាស់ប្តូរអ្នកដឹកនាំដោយអហិង្សាតាមរយៈសន្លឹកឆ្នោត មិនមែនដោយគ្រាប់កាំភ្លើងឡើយ។

## ៦. តំរូវការលទ្ធិប្រជាធិបតេយ្យ :

លទ្ធិប្រជាធិបតេយ្យត្រូវការឱ្យមានពហុភាព ព្រោះថា : មនុស្ស និងក្រុមមនុស្ស យើងតែងតែមានជំនឿ និងគំនិតប្លែកៗពីគ្នា។ មនុស្សដែលរស់នៅក្នុងសង្គមប្រជាធិប-តេយ្យ មិនត្រូវគិតថាមានតែក្រុមខ្លួនទេ ដែលឈ្នះរហូត ឬថាមានតែក្រុមខ្លួនទេដែលមានគំនិតល្អលើសគេនោះ ពោលគឺ ត្រូវគិតថានៅមានក្រុមដទៃទៀតដែល អាចនឹងឈ្នះខ្លួននៅពេលក្រោយ ហើយនៅមានគំនិតនៃក្រុម ដទៃទៀតដែលអាចនឹងល្អជាង យើងផងដែរ។ ច្បាប់ មតិភាគច្រើនត្រូវតែឈ្នះ និងត្រូវតែការពារគំនិត និងទស្សនៈភាគតិចផងក៏ដូចគ្នានឹងគណបក្សចាញ់ ឆ្នោតត្រូវតែប្រគល់អំណាចទៅគណបក្សដែលឈ្នះ ឆ្នោតជាដាច់ខាត ព្រោះថាការប្រគល់អំណាចឱ្យ នោះគ្រាន់តែជាកាប្រគល់ឱ្យបណ្តោះអាសន្នតែប៉ុណ្ណោះ។ ថ្ងៃក្រោយគណបក្សចាញ់អាចមានឱកាសត្រឡប់មកកាន់អំណាចវិញនៅពេលបោះឆ្នោតឈ្នះលើកក្រោយ។

## ៧. លទ្ធិប្រជាធិបតេយ្យមានលក្ខណៈពេញលេញ :

ប្រជាពលរដ្ឋក្នុងលោកនេះតែងតែចង់បាននូវ គោលការណ៍មូលដ្ឋានមួយចំនួនដើម្បីឱ្យរដ្ឋាភិបាល មានលក្ខណៈប្រជាធិបតេយ្យ។ នៅក្នុងសង្គមប្រជាធិបតេយ្យគោលការណ៍ទាំងនេះបានក្លាយជាសមាសភាពនៃរដ្ឋធម្មនុញ្ញ។ ថ្វីត្បិតតែប្រទេសប្រជាធិបតេយ្យនានាមានលក្ខណៈមិនដូចគ្នាបេះបិតក៏ដោយ ក៏ប្រជាពលរដ្ឋនៅប្រទេសប្រជាធិបតេយ្យតែងតែស្រឡាញ់ និងគាំទ្រគោលការណ៍ដូចៗគ្នា ហើយមានបំណងចង់បាន ផលប្រយោជន៍ ដូចៗគ្នាអំពីរដ្ឋាភិបាលខ្លួន។ គោលការណ៍ទាំងនេះជាខ្នាតគំរូអន្តរជាតិសំរាប់ឱ្យប្រជាធិបតេយ្យមានលក្ខណៈពេញលេញ៖

១- **មានការរួមចំណែកពីពលរដ្ឋ** គឺពលរដ្ឋមិនត្រឹមតែមានសិទ្ធិទេ ថែមទាំងមានកាតព្វកិច្ចទៀតផង។ ការរួមចំណែករបស់ពលរដ្ឋក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ រួមមានការបោះឆ្នោត ការឈរឈ្មោះឱ្យគេបោះឆ្នោត ការរួមប្រជុំ ការបញ្ចេញមតិ ការបង់ពន្ធដារ ប្រតិបត្តិតាមច្បាប់ និងការឃ្លាំមើលដំណើរការរបស់រដ្ឋាភិបាល គឺជាកាតព្វកិច្ចរបស់ពលរដ្ឋ ដើម្បីជួយកែលំអលទ្ធិប្រជាធិបតេយ្យ។

២- **មានការស្មើភាពគ្នា** ៖ ក្នុងសង្គមប្រជាធិបតេយ្យ គោលការណ៍ស្មើភាពមានន័យថា មនុស្សគ្រប់រូប មានតំលៃ និងមានលទ្ធភាពដូចគ្នា ដោយគ្មានការរើសអើង ។

៣- **មានការអនុគ្រោះគ្នា** ៖ សង្គមប្រជាធិបតេយ្យ គឺជាសង្គមដែលប្រកបដោយសេចក្ដីអនុគ្រោះ។ មានន័យថា ក្នុងពេលដែលបក្សឈ្នះ សិទ្ធិគ្រប់គ្រង អំណាចពួកគេត្រូវអនុគ្រោះ និងទទួលស្គាល់សិទ្ធិគ្រប់បែបយ៉ាងរបស់មនុស្សភាគតិច (ឬបក្សដែលចាញ់) ។ ត្រូវអនុគ្រោះ និងអនុញ្ញាតឱ្យបក្សចាញ់ ប្រើសិទ្ធិបញ្ចេញមតិជំទាស់។ រីឯនៅក្នុងសង្គមវិញ មនុស្សម្នាក់ក៏ត្រូវចេះអត់ឱនឱ្យគ្នា ទៅវិញទៅមកផងដែរ ។

៤- **មានការទទួលខុសត្រូវ** ៖ នៅក្នុងសង្គមប្រជាធិបតេយ្យ មន្ត្រីគ្រប់ជាន់ថ្នាក់ត្រូវមានការទទួលខុស ត្រូវចំពោះប្រជារាស្ត្រ។ ពួកគេត្រូវបំពេញភារកិច្ចតាមឆន្ទៈប្រជាពលរដ្ឋ និងដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋ ។

៥- **មានតម្លាភាព** ៖ រឿងអ្វីៗដែលរដ្ឋាភិបាលធ្វើត្រូវតែឱ្យប្រជាពលរដ្ឋបានដឹងឮ នេះមានន័យថា ត្រូវអនុញ្ញាតឱ្យអ្នកកាសែត និងប្រជាពលរដ្ឋសាកសួរព័ត៌មានអំពីកិច្ចការរបស់រដ្ឋាភិបាល ។

## ៨. សារៈសំខាន់នៃលទ្ធិប្រជាធិបតេយ្យ

ក) **ការទំនាក់ទំនងក្នុងសង្គម** ៖ ប្រជាធិបតេយ្យគឺជាការដែលបុគ្គលមួយរូប ឬអង្គការស្ថាប័ននីមួយៗត្រូវចេះទំនាក់ទំនងគ្នានៅក្នុងជីវភាពនយោបាយប្រចាំថ្ងៃ។ ដូច្នេះលទ្ធិប្រជាធិបតេយ្យទាមទារឱ្យមនុស្សក្នុងសង្គមមានអត្តចរិតល្អ ពោលគឺចេះអត់ឱនចំពោះអ្នកដែលមានមតិខុសពីខ្លួន ហើយចេះថ្លឹងថ្លែងចំពោះសេចក្ដីត្រូវការនៃក្រុមនានាតាមរយៈការពិភាក្សា ឬការចរចារ។ ការអត់ឱនឱ្យគ្នាទៅវិញទៅមកគឺជាការចាំបាច់សំរាប់ដំណើរការល្អរបស់លទ្ធិប្រជាធិបតេយ្យ។

ខ) **គោលការណ៍លើកស្ទួយលទ្ធិប្រជាធិបតេយ្យ** ៖ គោលការណ៍ចំបង៥ប្រការនៃការលើកស្ទួយសិទ្ធិមនុស្ស នៅក្នុងសង្គមដែលកាន់លទ្ធិប្រជាធិបតេយ្យគឺ ៖

១. ត្រូវមានច្បាប់ល្អ និងសណ្ដាប់ធ្នាប់ល្អ។

២. មិនត្រូវឱ្យមាននិរទណ្ឌភាព ពោលគឺជនល្មើស ត្រូវតែទទួលទណ្ឌកម្ម។

៣. ត្រូវមានការទទួលខុសត្រូវពេញលេញ ។

៤. មិនត្រូវឃុំឃាំងអ្នកទោសនយោបាយ ហើយមិន ត្រូវដោះលែងជនល្មើស ។

៥. ស្មើភាពគ្នាចំពោះមុខច្បាប់ ។

## ៩. ប្រទេសដែលមាននីតិរដ្ឋ ត្រូវមានលក្ខខណ្ឌចាំបាច់អ្វីខ្លះ ?

ប្រទេសដែលមាននីតិរដ្ឋ លុះត្រាតែប្រទេសនោះប្រកបដោយលក្ខខណ្ឌចាំបាច់ដូចតទៅ :

- ត្រូវមានតុលាការប្រកបដោយសមត្ថភាពវិជ្ជាជីវៈឥតលំអៀង និងឯករាជ្យពិតប្រាកដ មិនស្ថិតក្រោមអំណាចបុគ្គល ឬក្រុម បុគ្គលណាមួយ ។
- អ្នកគ្រប់គ្រងត្រូវប្រើប្រាស់អំណាចខ្លួនឱ្យស្របទៅតាមច្បាប់ មិនរំលោភអំណាច ឬយកអំណាចនោះទៅប្រើប្រាស់ដើម្បីផលប្រយោជន៍ខ្លួន និងបក្សពួក ថែមទាំងមិនជ្រៀតជ្រែកទៅក្នុងការងារតុលាការជាដើម ។
- ត្រូវមានរដ្ឋធម្មនុញ្ញដែលចែងទុកជាមុន អំពីការប្រើសិទ្ធិពេញលេញក្នុងការត្រួតពិនិត្យអំណាចនីតិប្រតិបត្តិ និងរដ្ឋបាល ដើម្បីកុំឱ្យអំណាចទាំងនេះរំលោភច្បាប់ ។
- ប្រជាពលរដ្ឋត្រូវមានសមភាពចំពោះមុខច្បាប់ទាំងអស់គ្នា មានន័យថា ប្រជាពលរដ្ឋគ្រប់រូប គ្រប់ជាន់ថ្នាក់ ត្រូវមានសិទ្ធិយករឿងក្តីខ្លួន ទៅប្តឹងផ្តល់ដល់សាលាជម្រះក្តី និងបានទទួលការវិនិច្ឆ័យដោយយុត្តិធម៌ដូចៗគ្នា ។
- សេរីភាពសារព័ត៌មាន : ប្រជាពលរដ្ឋត្រូវទទួលសិទ្ធិ និងសេរីភាពយ៉ាងពេញលេញក្នុងការបញ្ចេញមតិយោបល់ បង្កើតអង្គការសារព័ត៌មាន ស្ថានីយ៍វិទ្យុ ទូរទស្សន៍ ជាលក្ខណៈឯកជន ។

## ១០. សិទ្ធិមនុស្សជាមូលដ្ឋានមានអ្វីខ្លះ ?

**ក/សិទ្ធិពលរដ្ឋ :**

- សិទ្ធិរស់រានមានជីវិត ។
- សេរីភាពខាងជំនឿ និងមនសិការផ្ទាល់ខ្លួន ។
- សេរីភាពក្នុងការបញ្ចេញមតិ និងចូលរួមសមាគម ។
- សិទ្ធិធ្វើដំណើរដោយសេរី (ប៉ុន្តែបើចូលទៅប្រទេសដទៃត្រូវមានការអនុញ្ញាតពី

អាជ្ញាធរនៃប្រទេសនោះ ) ។

- សិទ្ធិតាំងទីលំនៅដោយសេរី ( ប៉ុន្តែត្រូវឱ្យសមស្របតាមច្បាប់សំណង់ ) ។
- សិទ្ធិការពារការរំលោភបំពានលើរាងកាយ និងផ្លូវចិត្ត ។
- ភាពស្មើគ្នាចំពោះមុខច្បាប់ និងតាមផ្លូវតុលាការ ។
- សិទ្ធិការពារការផែកឆៃរលំនៅដ្ឋានខុសច្បាប់ ។
- សិទ្ធិរួចចាកផុតពីអំណាចផ្តាច់ការរបស់រដ្ឋាភិបាល និងមានការការពារពីច្បាប់ ។

**ខ / សិទ្ធិនយោបាយ:**

- សេរីភាពក្នុងការនិយាយស្តី សារព័ត៌មាន ប្រជុំធ្វើសេចក្តីតវ៉ា ។
- សិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត ។
- សិទ្ធិចូលរួមបោះឆ្នោតដោយសេរី តាមឆន្ទៈ និងគ្មានការភ័យខ្លាច ។
- សេរីភាពបង្កើតសមាគម ឬ គណបក្សនយោបាយ ។
- សិទ្ធិចូលរួមក្នុងឆាកនយោបាយ (សិទ្ធិធ្វើយុទ្ធនាការសម្រាប់គណបក្សនយោបាយ សិទ្ធិចូលរួមក្នុងបក្សនយោបាយ និងសិទ្ធិលាឈប់ពីសមាជិកគណបក្សនយោបាយ) ។
- សិទ្ធិមានលទ្ធភាពស្មើគ្នាចំពោះសេវាកម្មសាធារណៈ (រួមទាំងសិទ្ធិទទួលការជ្រើសរើសឱ្យកាន់តំណែងការងារ) ។

**គ / សិទ្ធិសេដ្ឋកិច្ច និងសង្គម :**

- សិទ្ធិមានកម្មសិទ្ធិផ្ទាល់ខ្លួន ( ការដាក់ជាសម្បត្តិរួមដូចសម័យខ្មែរក្រហម គឺជាការរំលោភ) ។
- សិទ្ធិទទួល ( ដោយទិញជូន ឬអំណោយប្រើប្រាស់ផ្ទេរ និងឱ្យទៅគេដោយលក់ដូរ ឬធ្វើអំណោយ ឬបោះបង់ចោលនូវទ្រព្យសម្បត្តិ) ។
- សិទ្ធិជ្រើសរើសការងារ ឬផ្លាស់ប្តូរការងារ (គឺមិនបង្ខំឱ្យធ្វើការងារដោយផ្ទុយនឹងឆន្ទៈ ឬផ្ទុយពីសមត្ថភាព និងមុខជំនាញឡើយ) ។
- សិទ្ធិចូលរួមក្នុងសហជីព សមាគមវិជ្ជាជីវៈ សិទ្ធិធ្វើមុខជំនួញ និងសិទ្ធិធ្វើកិច្ចសន្យា

ស្របច្បាប់ ។

- សិទ្ធិមានម្ហូបអាហារគ្រប់គ្រាន់ ។
- សិទ្ធិមានគ្រួសារ និងគូស្រករ ។
- សិទ្ធិមានសន្តិសុខសង្គម
- សិទ្ធិមានពេលសំរាក និងកំសាន្តកាយ (ជនណាក៏ដោយមានសិទ្ធិធ្វើការមានកំណត់ពេលម៉ោងត្រឹមត្រូវ និងមានពេលសំរាកកំសាន្ត) ។
- សិទ្ធិទទួលការអប់រំ (មនុស្សគ្រប់រូបត្រូវតែមានចំណេះដឹង។ សង្គម និងរដ្ឋមានកាតព្វកិច្ចចាំបាច់ធ្វើឱ្យពលរដ្ឋគ្រប់រូបបានរៀនសូត្រ) ។

**ឃ/សិទ្ធិវប្បធម៌ :**

- សិទ្ធិដើម្បីមានចំណេះដឹង និងសិទ្ធិអាស្រ័យផលវប្បធម៌ និងរក្សាសិទ្ធិ ។
- សិទ្ធិនិយាយភាសាដើមរបស់ខ្លួន និងសិទ្ធិប្រកាន់ទំនៀមទម្លាប់ ប្រពៃណី ជំនឿសាសនា របស់ខ្លួន ។

**ង/សិទ្ធិមានបរិស្ថាន និងសិទ្ធិអភិវឌ្ឍន៍**

- សិទ្ធិរស់នៅក្នុងបរិស្ថានមួយបរិសុទ្ធ ។
- សិទ្ធិការពារការបំផ្លិចបំផ្លាញបរិស្ថាន និងសិទ្ធិអភិវឌ្ឍន៍សហគមន៍ ។

# ការបោះឆ្នោត និងសិទ្ធិអ្នកបោះឆ្នោត




## ១១. តើការបោះឆ្នោតមានសារៈសំខាន់អ្វីខ្លះ?

- ជ្រើសរើសអ្នកដឹកនាំដែលយើងពេញចិត្ត និងតាមឆន្ទៈ ។
- ផ្លាស់ប្តូរអ្នកដឹកនាំដោយសន្តិវិធី ។
- ទម្លាក់តំណាងដែលយើងមិនពេញចិត្ត ។
- ធ្វើឱ្យអ្នកដឹកនាំមានការគាំទ្រពីប្រជាពលរដ្ឋភាគច្រើន ។
- ធ្វើឱ្យតំណាងប្រជាពលរដ្ឋថ្នាក់ជាតិ និងឃុំ-សង្កាត់ និងរដ្ឋាភិបាល ទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋ។

## ១២. អ្វីជាការបោះឆ្នោតដោយសេរី ?

មានការចូលរួមដោយសេរីរបស់អ្នកបោះឆ្នោត បេក្ខជន និងគណបក្សនយោបាយ។

### ■ សេរីភាពរបស់អ្នកបោះឆ្នោត

ការបោះឆ្នោតដោយសេរីមានន័យថា :

- អ្នកបោះឆ្នោតអាចទទួលព័ត៌មានអំពីដំណើរការបោះឆ្នោត ដោយសេរី និងគ្រប់

ដំណើរការនៃការបោះឆ្នោត ។

- មានការចូលរួមប្រជុំដោយសេរី និងការបញ្ចេញមតិយោបល់ ដើម្បីពិភាក្សាអំពីបេក្ខជន បេក្ខនារី និងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។
- អ្នកបោះឆ្នោតសំរេចចិត្តបោះឆ្នោតតាមឆន្ទៈរបស់ខ្លួនពិតប្រាកដ ដោយគ្មានការគំរាមកំហែង គ្មានការបង្ខំឱ្យបោះឆ្នោតគាំទ្រគណបក្សណាមួយ គ្មានការទិញសន្លឹកឆ្នោត គ្មានអំពើហិង្សា ។

■ **សេរីភាពរបស់បេក្ខជន និងគណបក្សនយោបាយ**

បេក្ខជនគ្រប់គណបក្សនយោបាយមានសិទ្ធិចូលរួមឈរឈ្មោះដោយសេរី គ្មានការគំរាមកំហែង ការបំភិតបំភ័យ និងមានសិទ្ធិធ្វើសកម្មភាពឃោសនាដោយសេរី គ្មានការរារាំង ការរំខាន និងមានសុវត្ថិភាព ។ គណបក្សអាចពង្រីកបណ្តាញ និងជ្រើសរើសសមាជិកសកម្មជនដោយសេរី ។

■ **សេរីភាពរបស់អ្នកសង្កេតការណ៍**

- អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងភ្នាក់ងាររបស់គណបក្សនយោបាយ អាចចូលរួមសង្កេតការណ៍ តាមដាន និងធ្វើរបាយការណ៍លើរាល់សកម្មភាពនៃដំណើរការបោះឆ្នោតបានដោយសេរី និងទូលំទូលាយ ។
- ប្រជាពលរដ្ឋគួរត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតការណ៍លើដំណើរការចុះឈ្មោះបោះឆ្នោត ថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោតផងដែរ ។

## ១៣. អ្វីជាការបោះឆ្នោតដោយយុត្តិធម៌ ?

■ ការបោះឆ្នោតដោយយុត្តិធមិ គឺមិនមានការក្លែងបន្លំសន្លឹកឆ្នោត ឬការលួចដូរសន្លឹកឆ្នោត គ្មានការប្រើប្រាស់មធ្យោបាយទុច្ចរិតផ្សេងៗ ។

■ អាជ្ញាធររៀបចំការបោះឆ្នោតឯករាជ្យ អព្យាក្រឹត ស្អាតស្អំ តម្លាភាព និងមានការជឿជាក់ពីសាធារណជន ។

■ មានប្រព័ន្ធបោះឆ្នោតល្អ មាននិយ័តភាព ( ការបាះឆ្នោតត្រូវធ្វើឡើងដោយទៀងទាត់ក្នុងរយៈពេលកំណត់ប្រាំឆ្នាំម្តង) ។

- ■ ការដោះស្រាយវិវាទបោះឆ្នោតមានភាពយុត្តិធម៌ ត្រឹមត្រូវតាមច្បាប់ មានតម្លាភាព ។

## ១៤. អ្វីជាការបោះឆ្នោតដោយស្មើភាព ?

- ■ គណបក្សនយោបាយ និងបេក្ខជនទាំងអស់មានឱកាសស្មើគ្នាក្នុងការប្រកួតប្រជែង
- ■ នៅអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត គណបក្សនយោបាយចូលរួមប្រកួតប្រជែងទាំងអស់ ស្មើភាពគ្នាក្នុងការប្រើប្រាស់ប្រពន្ធ័ផ្សព្វផ្សាយរដ្ឋ ដូចជា ទូរទស្សន៍ វិទ្យុ មានសិទ្ធិប្រើសេវាសាធារណៈដូចៗគ្នា អាចប្រើសិទ្ធិរួមប្រជុំ មហាជនតាមកន្លែងសាធារណៈ តាមគ្រប់រូបភាព និងមធ្យោបាយដោយស្មើភាព គ្នាដើម្បីបង្ហាញពីកម្មវិធីនយោបាយ និងសមត្ថភាពរបស់ខ្លួនជូនប្រជាពលរដ្ឋ ។
- ■ អ្នកបោះឆ្នោតមានសិទ្ធិបោះឆ្នោតបានតែ១ដងគត់ ស្មើនឹង១សន្លឹក ក្នុង១អាណត្តិ ។ សន្លឹកឆ្នោត១សន្លឹកមានតម្លៃស្មើគ្នានៅគ្រប់មណ្ឌលបោះឆ្នោត ខេត្ត-ក្រុងទាំងអស់ ទោះបីអ្នកបោះឆ្នោតមានឋានៈ ជានាយករដ្ឋមន្ត្រី អភិបាលខេត្ត អភិបាលស្រុក ជាព្រះសង្ឃ ជាមេឃុំ ឬប្រជាពលរដ្ឋសាមញ្ញក៏ដោយ ។

## ១៥. តើភាគីពាក់ព័ន្ធណាខ្លះ ដែលចូលរួមជំរុញឱ្យមានការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ?

- ■ **មន្ត្រីរាជការ អាជ្ញាធរមូលដ្ឋាន កងកំលាំងប្រដាប់អាវុធ** ត្រូវមានជំហរ អព្យាក្រឹត ថែរក្សាសន្តិសុខ ស្ថិរភាពនយោបាយ គោរពសិទ្ធិមនុស្ស គោរពច្បាប់ ។
- ■ **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (គ.ជ.ប)
  - ត្រូវតែជាស្ថាប័នឯករាជ្យ អព្យាក្រឹត ឥតលំអៀង តម្លាភាព មិនមាននិន្នាការនយោបាយ ។
  - មានសមត្ថភាពអនុវត្តសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវក្នុងការរៀបចំចាត់ចែង និងគ្រប់គ្រងដំណើរការបោះឆ្នោត ។
  - ផ្តល់ភាពយុត្តិធម៌ អព្យាក្រឹត និងប្រសិទ្ធភាពក្នុងការដោះស្រាយវិវាទ និងបទល្មើសបោះឆ្នោត ។

- ចាត់វិធានការនានាក្នុងការបង្ការ និងទប់ស្កាត់បទល្មើស និងភាពមិន ប្រក្រតីក្នុងដំណើរការបោះឆ្នោត ។
- ធានាបរិយាកាសសំរាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ។

## ■ គណបក្សនយោបាយ

- គោរពគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស គោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់គ.ជ.ប និងគោរពក្រមសីលធម៌សំរាប់គណបក្សនយោបាយ ។
- ត្រូវមានសុឆន្ទៈ ការអត់អោន អធ្យាស្រ័យ និងគំនិតពហុនិយម ។
- មិនត្រូវប្រើប្រាស់មធ្យោបាយខុសច្បាប់ដូចជា ការទិញសន្លឹកឆ្នោត ការគំរាមកំហែង បំភិតបំភ័យ ប្រើសំដីប្រមាថមើលងាយ បង្ខំឱ្យធ្វើសម្បថ បង្ខំឱ្យផ្តិតមេដៃ ប្រើអំពើហិង្សា និងការសំលាប់ទៅលើបេក្ខជនឈរឈ្មោះ ឬសកម្មជន ឬអ្នកគាំទ្រគណបក្សនយោបាយ ។
- ត្រូវចូលរួមតាមដាន សង្កេតការណ៍គ្រប់ដំណើរការនៃការបោះឆ្នោត ។
- គណបក្សចាញ់ឆ្នោត និងគណបក្សដែលទទួលបានអាសនៈតិចត្រូវប្រគល់អំណាចឱ្យគណបក្សឈ្នះ ដោយសន្តិវិធី និងការពេញចិត្ត ។

## ■ អ្នកបោះឆ្នោត

- ត្រូវចុះឈ្មោះបោះឆ្នោត និងពិនិត្យបញ្ជីឈ្មោះឱ្យបានត្រឹមត្រូវ ។
- ចូលរួមស្តាប់ និងស្វែងយល់ព័ត៌មាន ស្តីពីដំណើរការបោះឆ្នោត (ការចុះឈ្មោះ នីតិវិធីបោះឆ្នោត ការអប់រំផ្សេងៗ) ហើយផ្សព្វផ្សាយបន្តដល់អ្នកជិតខាង មិត្តភ័ក្តិរបស់ខ្លួន ។
- ឈ្លាសវៃក្នុងការដោះស្រាយបញ្ហាដោយសន្តិវិធី ដើម្បីសុវត្ថិភាព នៅពេលជួបនឹងឧបាយកលទុច្ចរិតរបស់គណបក្សនយោបាយ ឬសកម្មជនគណបក្សមានដូចជាការលួងលោម ការបង្ខិតបង្ខំ ការគំរាម កំហែងឱ្យបោះឆ្នោត

គាំទ្រគណបក្សណាមួយ ។

- ពេលឃើញភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោត អំពើហិង្សា ការទិញសន្លឹកឆ្នោត ការកត់លេខប័ណ្ណបោះឆ្នោត ការបង្ខំឱ្យស្បថ... អ្នកបោះឆ្នោតត្រូវផ្ដល់ព័ត៌មានដល់អ្នកសង្កេតការណ៍ ឬរាយការណ៍ទៅស្ថាប័នរៀបចំការបោះឆ្នោត និងអាជ្ញាធរដែនដី ។
- បោះឆ្នោតតាមឆន្ទៈ និងការពេញចិត្តរបស់ខ្លួន
- មិនត្រូវបោះឆ្នោតតាមការទទួលអំណោយ ការគំរាមកំហែង ការទិញសន្លឹកឆ្នោត និងការលួងលោមទេ ។

■ **ប្រពន្ធ័ផ្សព្វផ្សាយព័ត៌មាន**

- ត្រូវផ្ដល់ពេលវេលាផ្សព្វផ្សាយឱ្យបានគ្រប់គ្រាន់ដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីប្រើប្រាស់ក្នុងការឃោសនាបោះឆ្នោត និងអប់រំអ្នកបោះឆ្នោត ។
- ត្រូវគោរពគោលការណ៍ស្មើភាពគ្នាក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់គណបក្សនយោបាយតាមរយៈវិទ្យុ ទូរទស្សន៍ សារព័ត៌មាន... ។
- ត្រូវបើកទូលាយ និងបង្កភាពងាយស្រួលដល់សមាគម អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ដែលធ្វើការអប់រំផ្សព្វផ្សាយ ផ្ដល់ព័ត៌មាន និងចំណេះដឹងដល់អ្នកបោះឆ្នោត តាមរយៈវិទ្យុ ទូរទស្សន៍ ទីសាធារណៈទូទាំងប្រទេស និង
- ត្រូវប្រកាន់ជំហរអព្យាក្រឹត និងរក្សាឯករាជ្យភាពរបស់ខ្លួន ។

■ **អ្នកសង្កេតការណ៍ :**

- ត្រូវមានជំហរឯករាជ្យ អព្យាក្រឹត គ្មាននិន្នាការនយោបាយ និងប្រកាន់សច្ចភាព ។
- ត្រូវចូលរួមសង្កេតការណ៍លើគ្រប់ដំណើរការនៃការបោះឆ្នោត ។
- ត្រូវទទួលការអប់រំ បណ្ដុះបណ្ដាលពីជំនាញសង្កេតការណ៍ យកព័ត៌មាន និង

សេរ សេររបាយការណ៍ ។

- ត្រូវតែក្លាហានចូលរួមក្នុងការសង្កេតការណ៍ ទោះបីមានឧបសគ្គ ឬការគំរាមកំហែងក៏ដោយ ពីព្រោះយើងគ្រាន់តែបំពេញតួនាទីរបស់ខ្លួនជាអ្នកសង្កេតការណ៍ដោយឯករាជ្យ និងគ្មាននិន្នាការនយោបាយ ។
- ទទួលពាក្យបណ្តឹងអំពីភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោត ហើយបញ្ជូនទៅស្ថាប័នពាក់ព័ន្ធដើម្បីមានវិធានការ និងអន្តរាគមន៍ ។
- ហ៊ាននិយាយ ផ្តល់យោបល់ បញ្ចេញមតិ និងហ៊ានដោះស្រាយបញ្ហាដែលខ្លួនបានឃើញ ដើម្បីបង្កើននូវទំនុកចិត្តពីសាធារណជន និងជំរុញឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយភាពសេរី យុត្តិធម៌ និងតម្លាភាព ។

## ១៦. តើអ្នកបោះឆ្នោតប្រើប្រាស់សិទ្ធិអំណាចយ៉ាងណាចំពោះតំណាងជាប់ឆ្នោតដែលមិនបំរើផលប្រយោជន៍របស់ប្រជាពលរដ្ឋ ?

- ក្រោយពេលបោះឆ្នោត អ្នកបោះឆ្នោតត្រូវតែតាមដាន សង្កេត និងវាយតម្លៃលើសកម្មភាព និងការអនុវត្តន៍ការសន្យារបស់អ្នកតំណាងជាប់ឆ្នោតរបស់ខ្លួន និងគណបក្សជាប់ឆ្នោត ។ អ្នកតំណាងដែលជាប់ឆ្នោត (តំណាងរាស្ត្រ និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់) បានទទួលអំណាចពីប្រជាពលរដ្ឋតាមរយៈការបោះឆ្នោត ត្រូវតែបំរើផលប្រយោជន៍ និងបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។
- បើអ្នកតំណាងជាប់ឆ្នោតមិនបានបំរើផលប្រយោជន៍ប្រជាពលរដ្ឋមិនអនុវត្តតាមការសន្យារបស់ខ្លួន ប្រជាពលរដ្ឋអាចប្រើប្រាស់អំណាចរបស់ខ្លួន ដោយស្នើសុំឱ្យអ្នកតំណាងនោះគោរពការសន្យារបស់ខ្លួន ឬសុំឱ្យអ្នកតំណាងនោះលាចេញពីតំណែងមុនពេលកំណត់ ឬ ប្រជាពលរដ្ឋអាចធ្វើពាក្យបណ្តឹងទៅសាមីគណបក្សនយោបាយនៃអ្នកតំណាងនោះនៅអាណត្តិក្រោយ ឱ្យធ្វើការផ្លាស់ប្តូរអ្នកតំណាងរូបនោះចេញ ឬ ជំរើសចុងក្រោយប្រជាពលរដ្ឋមិនបោះឆ្នោតគាំទ្រអ្នកតំណាងរូបនោះឬគណបក្ស នយោបាយរបស់អ្នកតំណាងនោះ ហើយប្រជាពលរដ្ឋបោះឆ្នោតឱ្យអ្នកតំណាងថ្មី ផ្សេងទៀតដែលខ្លួនពេញចិត្ត សង្ឃឹមថាអាចដោះស្រាយបញ្ហា

យើងបាន។

- ប្រសិនបើកំហុសរបស់អ្នកតំណាង (ជាបុគ្គល ឬគណបក្សនយោបាយ) មានលក្ខណៈធ្ងន់ធ្ងរ ដូចជា ការកេងប្រវ័ញ្ចជាតិ អំពើពុករលួយធ្ងន់ធ្ងរមិនដោះស្រាយបញ្ហាជាតិ ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដូចជាការសំលាប់មនុស្ស។ល។ ក្នុងអាណត្តិដែលខ្លួនមានអំណាច ប្រជាពលរដ្ឋត្រូវប្រើសិទ្ធិអំណាចខ្លួន អំពាវនាវប្តឹងទៅសភា ព្រឹទ្ធសភា តុលាការឯករាជ្យ ឬប្រើប្រាស់សិទ្ធិបញ្ចេញមតិ និងមហាបាតុកម្មដោយសន្តិវិធី ដើម្បីបង្ខំឱ្យអ្នកតំណាងនោះចុះពីតំណែងមុនអាណត្តិ ។

## ១៧. តើលោក អ្នកត្រូវដោះស្រាយយ៉ាងណា នៅពេលជួប ឬប្រឈមមុខជាមួយនឹងឧបាយកលទុច្ចរិតក្នុងដំណើរការបោះឆ្នោត ?

ឧបាយកលទុច្ចរិតមានដូចជា : ការគំរាមកំហែង ការបំភិតបំភ័យ ការទិញសន្លឹកឆ្នោត (ដោយសម្ភារៈ ឬប្រាក់កាស) ការលួងលោមទិញទឹកចិត្ត ការបង្ខំឱ្យធ្វើសម្បថ ការកត់លេខប័ណ្ណបោះឆ្នោត... ។

- ប្រជាពលរដ្ឋត្រូវរាយការណ៍ជាសម្ងាត់ដល់អ្នកសង្កេតការណ៍ ឬភ្នាក់ងាររបស់គណបក្សនយោបាយ ដែលលោកអ្នកទុកចិត្ត។ ប៉ុន្តែបើលោក អ្នកជួបបញ្ហាចំពោះមុខ គេកំពុងគំរាមកំហែង លោក អ្នកត្រូវដោះស្រាយ ដោយភាពទន់ភ្លន់ដូចជា :
- បើលោក អ្នកនិយាយទៅដោយគ្មានផលវិបាក ឬគ្រោះថ្នាក់ដល់ខ្លួនទេនោះ លោកអ្នកអាចនិយាយថា "*ក្នុងពេលនេះខ្ញុំពុំទាន់ធ្វើការសំរេចចិត្តនៅឡើយទេ សូមអភ័យទោស*"។
- បើចៀសមិនរួច លោក អ្នកត្រូវតែទទួលយក គួរប្រើពាក្យយ៉ាងទន់ភ្លន់ថា "*ខ្ញុំនឹងបោះឆ្នោតឱ្យលោក ឬគណបក្សរបស់លោក* "។

**ប៉ុន្តែ** ប្រការដែល**ត្រូវចងចាំ**នោះគឺ ការបោះឆ្នោតជា **ការសម្ងាត់** គ្មានអ្នកណាដឹងថាលោក អ្នកបោះឆ្នោតឱ្យគណបក្សណាមួយទេ។ ដូចនេះ លោក អ្នកត្រូវបោះឆ្នោះ**តាមឆន្ទៈ និងការពេញចិត្ត**របស់ខ្លួន។

## ១៨. តើអ្វីខ្លះជាភាពឈ្លាសវៃរបស់អ្នកបោះឆ្នោត ?

- អ្នកបោះឆ្នោត ត្រូវ/ចេះ ស្វះស្វែង ព្យាយាម តាមដានដោយយកចិត្តទុកដាក់រាល់ការអប់រំ ផ្សព្វផ្សាយ ផ្តល់ព័ត៌មាន អំពីការបោះឆ្នោត របស់ស្ថាប័នរៀបចំការបោះឆ្នោត សមាគម-អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល និងចេះអប់រំផ្សព្វផ្សាយបន្ត ដល់បងប្អូនប្រជាពលរដ្ឋជិតខាង និងមិត្តភ័ក្តិរបស់ខ្លួន ។
- អ្នកបោះឆ្នោតចេះដោះស្រាយនូវបញ្ហានានា (ឧបាយកលទុច្ចរិត) ពេលដែលខ្លួនជួប ឬប្រឈមមុខក្នុងកំឡុងពេលបោះឆ្នោតដោយសន្តិវិធី ដោយភាពវៃឆ្លាតដើម្បីសុវត្ថិភាព ។
- ពិនិត្យមើលបុគ្គលិកលក្ខណៈរបស់បេក្ខជន បេក្ខនារីឈរឈ្មោះ និងគោលនយោបាយរបស់គណបក្សនយោបាយនីមួយៗ ។
- បោះឆ្នោតតាមឆន្ទៈរបស់ខ្លួន ទោះបីគេគំរាមកំហែង យកសំភារៈ ឬលុយទិញទឹកចិត្ត បង្ខំឱ្យធ្វើសម្បថ ឬប្រើសកម្មភាពបង្ខិតបង្ខំយ៉ាងណាក៏ដោយ ដោយលោក អ្នកត្រូវយល់ពីគោលការណ៍នៃការបោះឆ្នោត ***"បោះឆ្នោតដោយសំងាត់ តាមឆន្ទៈ ដោយសេរី និងស្មើភាព"*** ។




បោះឆ្នោតដើម្បីកាត់បន្ថយភាពក្រីក្រ ដោះស្រាយបញ្ហា និងអនាគតពួកយើង

# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
# សិទ្ធិ និង នីតិវិធី

## ១៩. តើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សំរាប់អាណត្តិប៉ុន្មានឆ្នាំ?

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវ ធ្វើឡើងជាទៀតទាត់ក្នុងរយៈពេលប្រាំ(០៥)ឆ្នាំម្តង ។

## ២០. បញ្ហាសំខាន់ដែលអាចលើកមកពិភាក្សាក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅកម្ពុជាមានអ្វីខ្លះ ?

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺ :

- ដើម្បីបំបាត់អំពើពុករលួយ
- ដើម្បីកាត់បន្ថយភាពក្រីក្រ
- ដើម្បី ដោះស្រាយបញ្ហា (រំលោភសិទ្ធិមនុស្សហិង្សា រំលោភសេពសន្ថវៈលើស្ត្រី និងកុមារ បញ្ហាដីធ្លី ចោរកម្មឃាតកម្ម ចាប់ជំរិតទារប្រាក់ គ្រឿងញៀន ។ល។ និង ។ល។
- ដើម្បីរកទីផ្សារសំរាប់ផលិតផលក្នុងស្រុករបស់ប្រជាពលរដ្ឋ ។

## ២១. តើអ្វីខ្លះជាគោលការណ៍សំខាន់ៗសំរាប់អ្នកបោះឆ្នោត ?

▪ **បោះឆ្នោតដោយ " សំងាត់ " :** ត្រូវយល់ថា ការសម្ងាត់របស់អ្នកបោះឆ្នោតត្រូវបានធានា នៅពេលដែលអ្នកបោះឆ្នោតចូលក្នុងបន្ទប់សំងាត់ គ្មាននរណាដឹងថា យើងបោះឆ្នោតឱ្យគណបក្សណាមួយឡើយ ។ សន្លឹកឆ្នោតមានលក្ខណៈដូចគ្នា គ្មានអ្វីសំគាល់ដឹងថា សន្លឹកឆ្នោតមួយនេះ ជារបស់អ្នកបោះឆ្នោតមួយនេះ ហើយសន្លឹកឆ្នោតមួយនោះ ជារបស់អ្នកបោះឆ្នោតមួយនោះទេ ។

▪ **បោះឆ្នោតតាម " ឆន្ទៈ " :** ត្រូវយល់ថា អ្នកបោះឆ្នោតត្រូវសំរេចចិត្តបោះឆ្នោតជ្រើសរើសតំណាង តាមការស្រឡាញ់ពេញចិត្តរបស់ខ្លួន ។

▪ **បោះឆ្នោតដោយ " សេរី " :** មានន័យថា

- សេរីភាពទទួលពត៌មានអំពីការបោះឆ្នោត និងព័ត៌មាន ផ្សេងៗដោយសេរី និង

តម្លាភាព ។

- មានការរួមផ្តុំ និងការបញ្ចេញមតិយោបល់ ដើម្បី ពិភាក្សាអំពី បេក្ខជន បេក្ខនារី និងគណបក្សឈរឈ្មោះបោះឆ្នោត ។
- មានការចូលរួមប្រជុំដោយសេរី និងការប្រើប្រាស់ មធ្យោបាយផ្សព្វផ្សាយ ដោយសេរី និងស្មើភាព ។ល។ និង ។ល។

## ២២. តើនឹងមានអ្វីកើតឡើង បើសិនជាលោក អ្នកមិនបានទៅបោះឆ្នោត ?

**លោក អ្នកត្រូវតែទៅបោះឆ្នោត!** ការបោះឆ្នោតមានសារៈសំខាន់ណាស់ក្នុងលទ្ធិប្រជាធិបតេយ្យ ដើម្បីជ្រើសរើសអ្នកដឹកនាំតាមការពេញចិត្តរបស់ប្រជាពលរដ្ឋដែលជា អ្នកបោះឆ្នោត។ បើលោក អ្នកមិនទៅបោះឆ្នោតទេ មានន័យថា អ្នកដទៃជាអ្នកសំរេចចិត្តក្នុងការជ្រើសរើសអ្នកដឹកនាំជំនួសលោកអ្នក ហើយលោកអ្នកបានលះបង់ចោលនូវ សិទ្ធិជាពលរដ្ឋក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិ។ម្យ៉ាងទៀត មានន័យថា លោកអ្នក បណ្តោយឱ្យអ្នកជាប់ឆ្នោតធ្វើអ្វីតាមតែអំពើចិត្តមិនបំរើផលប្រយោជន៍របស់ប្រជាពលរដ្ឋហើយប្រទេសជាតិគ្មានការរីកចំរើន។ ដូចនេះ លោកអ្នកត្រូវតែទៅបោះឆ្នោតជ្រើសរើស អ្នកដឹកនាំឱ្យបានត្រឹមត្រូវ ដើម្បីអភិវឌ្ឍប្រទេសជាតិ ព្រោះវាជាសិទ្ធិ និងករណីយកិច្ច របស់លោក-អ្នក និងជាឱកាសដ៏ល្អរបស់លោក អ្នកក្នុងការទម្លាក់អ្នកដឹកនាំដែលលោក អ្នកមិនពេញចិត្ត ។

កំលាំងចូលរួមរបស់លោក អ្នកក្នុងការបោះឆ្នោត និងជាមួយតំណាងជាប់ឆ្នោតប្រៀបដូចជាតំណក់ទឹកបំបែកផ្ទាំងសិលាមួយដ៏ធំ និងជាកំលាំងចលករជំរុញឱ្យមានការដោះស្រាយបញ្ហាទាំងឡាយក្នុងសង្គមមួយថ្ងៃបន្តិចៗ ដើម្បីពួកយើង កូនចៅជំនាន់ក្រោយ និងប្រទេសជាតិមានប្រជាធិបតេយ្យរឹងមាំ ។ ម្យ៉ាងទៀតការឈ្នះចាញ់របស់គណបក្សប្រកួតប្រជែងវាអាចអាស្រ័យទៅលើសន្លឹកឆ្នោតរបស់យើងមួយសន្លឹកនេះផងដែរ។

## ២៣. មុននឹងបោះឆ្នោត តើលោក អ្នកត្រូវពិនិត្យមើលបេក្ខជន បេក្ខនារីឈរឈ្មោះដូចម្តេចខ្លះ ?

- ដំបូងត្រូវពិនិត្យមើលបេក្ខជន/បេក្ខនារីឈរឈ្មោះនៃបញ្ជីគណបក្សថាតើមាន

ដាក់បេក្ខជន បេក្ខនារីឆ្លាស់គ្នានៅលេខរៀងខាងលើឬទេ? (អ្នកនៅលេខរៀងខាងលើ អាចមានលទ្ធភាពជាប់ច្រើន) មានលក្ខណៈសម្បត្តិយ៉ាងណាខ្លះ?

- បន្ទាប់មកបេក្ខជន/បេក្ខនារីនោះធ្លាប់ឈរឈ្មោះឬទេ នៅអាណត្តិមុនៗ
- បើគាត់ធ្លាប់ឈរឈ្មោះ តើបានជាប់ឆ្នោតឬទេ? ជាប់ឆ្នោតជាអ្វី? (ក្រុមប្រឹក្សាឃុំ-សង្កាត់ ឬតំណាងរាស្ត្រ)
- នៅពេលគាត់ជាប់ឆ្នោតក្នុងតំណែង តើគាត់យកចិត្តទុកដាក់ជាមួយប្រជាពលរដ្ឋក៏រិតណា? ហើយគួរបោះឆ្នោតឱ្យគាត់បន្តទៀត ឬមួយយ៉ាងណា ?
- បើគាត់មិនធ្លាប់ឈរឈ្មោះ តើគាត់ធ្លាប់ធ្វើការជាអ្វី?
(មន្ត្រីរាជការ, គ្រូបង្រៀន, ពេទ្យ អាចារ្យ អ្នករកស៊ី)
- ពេលពួកគាត់នៅធ្វើការ តើពួកគាត់ធ្វើការល្អឬទេ? យកចិត្តទុកដាក់ជាមួយប្រជាពលរដ្ឋឬទេ?
- បន្ទាប់មកត្រូវពិនិត្យថាបេក្ខជន-បេក្ខនារីធ្លាប់រកស៊ីខុសច្បាប់ បន្លំ ឆបោក ទារប្រាក់ពីប្រជាពលរដ្ឋ ឬប្រព្រឹត្តិអំពើហិង្សាក្នុងគ្រួសារ ឬឈ្លោះទាស់ទែងជាមួយអ្នកជិតខាងដោយមិនសមរម្យ រំលោភយកដីប្រជាពលរដ្ឋ ឬមានបញ្ហាផ្សេងៗទៀត ។
- តើគាត់មានគំនិតទូលំទូលាយ យល់ដឹងពីលិទ្ធប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស គំនិតអធ្យាស្រ័យ ដោះស្រាយបញ្ហាឬទេ?
- តើគាត់មានការប្តេជ្ញាចិត្តក្នុងការលើកនូវបញ្ហា និងតំរូវការរបស់ប្រជាពលរដ្ឋដាក់ជូនរដ្ឋាភិបាល ឬទេ?
- តើគាត់មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការដឹកនាំឃុំ-សង្កាត់ និងប្រទេសជាតិឱ្យរីកចំរើនបានឬទេ?
- សូមតាមដាន និងស្វែងយល់ បញ្ជីគណបក្សនយោបាយ ជាពិសេសទៅលើ បេក្ខជនបេក្ខនារី ឈរក្នុងលេខរៀងលើគេ (លទ្ធភាពអាចជាប់) ក្នុងគណបក្ស នីមួយៗ ព្រោះថា បេក្ខជន/ បេក្ខនារី នឹងពុំដាក់បង្ហាញក្នុង សន្លឹកឆ្នោតទេ។

## ២៤. តើអ្នកបោះឆ្នោត ត្រូវធ្វើការស្វែងយល់ពីគោលនយោបាយរបស់គណបក្សឬទេ ?

**ត្រូវតែស្វែងយល់ !** ព្រោះបេក្ខជន/បេក្ខនារីគឺជាសមាជិកគណបក្សនយោបាយ!

- ត្រូវពិនិត្យមើលគោលជំហរ និងគោលនយោបាយរបស់គណបក្សនយោបាយ ថាតើមាននិន្នាការទៅរកលទ្ធិប្រជាធិបតេយ្យ ការអភិវឌ្ឍសេដ្ឋកិច្ច (ចង់ឱ្យប្រជាពលរដ្ឋមានជីវភាពធូរធារ ឬទុកឱ្យប្រជាពលរដ្ឋនៅក្រីក្រ) ការគោរពសិទ្ធិមនុស្ស ការនិយមលទ្ធិផ្តាច់ការ ការប្រើប្រាស់អំណាចហួសហេតុ (ការតែងតាំងការដកបុគ្គលិក) ។
- ការទទួលខុសត្រូវរបស់គណបក្សនយោបាយ ការគោរពតាមការសន្យា
- ការរៀបចំរចនាសម្ព័ន្ធក្នុងគណបក្សមានលក្ខណៈប្រជាធិបតេយ្យ មានការផ្លាស់ប្តូរប្រធានគណបក្សឬទេ ? មានការបោះឆ្នោតផ្ទៃក្នុងគណបក្សឬទេ ? និងមានគោលនយោបាយលើកកំពស់សមភាពយេនឌ័រឬទេ ?
- អ្នកដឹកនាំគណបក្សនោះ ជានរណា ?

## ២៥. តើអ្វីខ្លះជាផលវិបាកនៃការទិញ លក់សន្លឹកឆ្នោត?

ប្រសិនជាលោកអ្នកបោះឆ្នោតដោយការទិញ លក់សន្លឹកឆ្នោត នោះវាធ្វើឱ្យ :

- លោក អ្នក ក្លាយជាទាសករនៃអំណាច
- លោកអ្នកត្រូវគិតថា ជំនួយតែងមានចំណងដូចពាក្យ ចាស់លោកពោលថា *"ហុចរបស់ស្រណោះដៃ"* ។
- លោក អ្នកបោះឆ្នោតតាមការទិញសន្លឹកឆ្នោត យើងនឹងបានអ្នកជាប់ឆ្នោតជាតំណាង មិនល្អ មិនជួយដោះស្រាយបញ្ហា និងឈានទៅប្រើប្រាស់អំណាចហួសហេតុ ប្រព្រឹត្តអំពើពុករលួយ ដើម្បីបានប្រាក់យកមកទិញសន្លឹកឆ្នោតនៅពេលបោះឆ្នោតលើកក្រោយទៀត ហើយកាន់អំណាចជារៀងរហូត ។
- បើយើងលក់សន្លឹកឆ្នោតយើងនៅតែជួបភាពក្រីក្រ គ្មានការអភិវឌ្ឍន៍នៅមណ្ឌលរបស់យើង អ្នកកាន់អំណាចមិនបង្កលក្ខណៈងាយស្រួលដល់ ប្រជាពលរដ្ឋក្នុង ការ

ប្រកបរបររកស៊ី និងការងារ ។

- សង្គមទទួលបាន ការរំលោភច្បាប់បោះឆ្នោត ការរំលោភអំណាច រំលោភច្បាប់ មិនគោរពសិទ្ធិមនុស្ស គ្មានប្រជាធិបតេយ្យ គ្មានយុត្តិធម៌ មានអំពើពុករលួយ គ្មានការអភិវឌ្ឍ និងបន្តភាពក្រីក្រ ។




លក់សន្លឹកឆ្នោត ក្លាយជាទាសករអំណាច ហើយនាំមកភាពក្រីក្រ គ្មានការដោះស្រាយបញ្ហា បំផ្លាញអនាគតពួកយើង

## ២៦. តើមានបញ្ហាអ្វីខ្លះអាចកើតឡើងក្នុងដំណើរការបោះឆ្នោត ?

- មានការទិញទឹកចិត្តតាមរយៈ សំភារៈ និងលុយកាក់ (ពិសេស ការទិញសន្លឹកឆ្នោតនៅយប់មុនថ្ងៃបោះឆ្នោតមួយថ្ងៃ) ។
- មានការបង្ខិតបង្ខំឱ្យប្រជាពលរដ្ឋធ្វើសម្បថ និងកត់លេខប័ណ្ណបោះឆ្នោត
- មានការគំរាមកំហែង បំភិតបំភ័យ បង្ខិតបង្ខំ ទៅលើប្រជាពលរដ្ឋ និងបេក្ខជន ឬជនសកម្មរបស់គណបក្សនយោបាយ ។
- ការរារាំង គំរាមកំហែងបេក្ខជនមិនឱ្យឈរឈ្មោះបោះឆ្នោត
- បង្កការលំបាក ឧបសគ្គដល់គណបក្សប្រឆាំង ឬគណបក្សតូចៗក្នុងការចុះបញ្ជីបេក្ខជនឈរឈ្មោះ ។

- អ្នកមានសិទ្ធិបោះឆ្នោតត្រូវបានបដិសេធមិនឱ្យចុះឈ្មោះបោះឆ្នោត
- ចុះឈ្មោះឱ្យអ្នកដែលគ្មានសិទ្ធិបោះឆ្នោត
- បាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ (នៅថ្ងៃបោះឆ្នោត)
- ក្នុងពេលយុទ្ធនាការឃោសនា មិនគោរពគោលការណ៍ស្មើភាព (ឃោសនាមុនកាលកំណត់...)
- មានអំពើហិង្សា និងការសំលាប់ខាងនយោបាយ
- មិនធានានូវសុវត្ថិភាព សន្តិសុខ
- មិនធានានូវសេរីភាពក្នុងការបញ្ចេញមតិ
- អ្នកបោះឆ្នោតត្រូវបានបញ្ចុះបញ្ចូល ដើម្បីរារាំងមិនឱ្យទៅបោះឆ្នោត
- មានភាពយឺតយ៉ាវក្នុងការដឹកជញ្ជូន និងផ្តល់សម្ភារៈបោះឆ្នោត
- មានភាពមិនប្រក្រតីក្នុងការដឹកជញ្ជូនហិបឆ្នោត
- មានភាពយឺតយ៉ាវក្នុងការរាប់សន្លឹកឆ្នោត
- ពេលរាប់សន្លឹកឆ្នោតមានការបន្លំ មានការរំខាន
- មានការរារាំងអ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយមិនឱ្យចូលរួមសង្កេតការណ៍។
- មានការយល់ច្រឡំជាមួយប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងឯកសារបញ្ជាក់អត្តសញ្ញាណ សំរាប់បោះឆ្នោត ដែលធ្វើឱ្យអ្នកបោះឆ្នោតត្រូវបានគេបដិសេធ ឬត្រូវបានដេញឱ្យទៅយកឯកសារបញ្ជាក់អត្តសញ្ញាណ នាំឱ្យអ្នកបោះឆ្នោតមានការធុនទ្រាន់លែងមកបោះឆ្នោត។

## ២៧. តើលោក អ្នកត្រូវតែចូលជាសមាជិករបស់គណបក្សនយោបាយណាមួយ ឬទេ ដើម្បីបាននៅបោះឆ្នោត ?

**<u>មិនចាំបាច់ទេ</u> !** ការបោះឆ្នោតគឺជាសិទ្ធិនយោបាយ និងជាសេរីភាពរបស់លោក អ្នក ដូចនេះ លោក អ្នកមិនចាំបាច់ចូលជាសមាជិកគណបក្សនយោបាយណាមួយឡើយ។ ទោះបីលោក អ្នកមិនមែនជាសមាជិកគណបក្សនយោបាយណាមួយក៏ដោយក៏លោក អ្នក

មានសិទ្ធិបោះឆ្នោតដោយសេរីបានដែរ ។

# យុទ្ធនាការឃោសនាបោះឆ្នោត




## ២៨. តើការឃោសនាបោះឆ្នោតមានបំណងអ្វី ?

ការឃោសនាបោះឆ្នោត មានទិសដៅឱ្យគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ-សង្កាត់ជូនដល់អ្នកបោះឆ្នោត ។

## ២៩. តើយុទ្ធនាការឃោសនាបោះឆ្នោតចាប់ផ្តើមនៅពេលណា និងបញ្ចប់នៅពេលណា?

- យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេល**សាមសិប** (៣០) **ថ្ងៃ** គឺចាប់ពីថ្ងៃទី **២៦ ខែមិថុនា** ដល់ថ្ងៃទី**២៥** ខែ**កក្កដា** ឆ្នាំ២០០៨ ហើយគ្រប់សកម្មភាព

នៃការឃោសនាបោះឆ្នោតត្រូវចប់ **ម្ភៃបួន (២៤) ម៉ោង** មុនថ្ងៃបោះឆ្នោត ( **មួយ (០១) ថ្ងៃមុន** ថ្ងៃបោះឆ្នោតហៅថា ***ថ្ងៃស*** ) ។

- គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវចាប់ផ្ដើមពីម៉ោងប្រាំមួយ( ៦ ) ព្រឹក ដល់ម៉ោងដប់ ( ១០ ) យប់ និង ត្រូវឈប់សម្រាកនៅចន្លោះពីម៉ោង ដប់( ១០ ) យប់ ដល់ម៉ោង ប្រាំមួយ( ៦ ) ព្រឹក ។
- សកម្មភាពឃោសនាដោយឧបករណ៍បំពងសម្លេង ត្រូវហាមឃាត់ចាប់ពីម៉ោងដប់ពីរ( ១២ ) ថ្ងៃត្រង់ ដល់ម៉ោងពីរ( ២ ) រសៀល ។

## ៣០. តើការឃោសនាបោះឆ្នោតធ្វើនៅកន្លែងណា ?

- ការឃោសនាបោះឆ្នោត ត្រូវធ្វើឡើងនៅតាមរោងវីដេអូសាធារណៈ ឬទីសាធារណៈ ។ ប្រជាពលរដ្ឋអាចសាកសួរព័ត៌មានពីគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោតអំពីទីកន្លែង និងគណបក្សដែលធ្វើការឃោសនា ។

## ៣១. តើសកម្មភាពអ្វីខ្លះដែលធ្វើឡើងក្នុងពេលឃោសនាបោះឆ្នោត ?

ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើឡើងជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យ បោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ ។

សកម្មភាពឃោសនារួមមាន :

- ការជួបជុំជាសាធារណៈ
- ក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ
- ការបញ្ចុះបញ្ចូលពីផ្ទះមួយទៅផ្ទះមួយ
- ការផ្សព្វផ្សាយតាមឧត្បោសនសព្ទ
- ស្រែកជាពាក្យស្លោកខ្លីៗតាមឧបករណ៍បំពងសម្លេង ឬតាមឧបករណ៍បញ្ចាំងរូបភាព
- ផ្សព្វផ្សាយតាមរយៈការចាក់កាសែតវីដេអូ ឬ វីស៊ីឌី ឬ ឌីវីឌី
- បិទផ្សាយនូវរូបភាពឃោសនា លើកបដា តំឡើងបន្ទះក្ដារបិទប្រកាសផ្សាយ

- ការចែកចាយខិត្តប័ណ្ណគណបក្ស មួក សំលៀកបំពាក់ អាវយឺត ផ្លាកសញ្ញា ឬសម្ភារៈផ្សេងៗទៀត
- ការប្រគុំតន្ត្រីដោយដើរជាក្បួន ឬច្រៀងចំរៀងឃោសនា ឬការលេងភ្លេងឃោសនា
- ព្រឹត្តិការណ៍កីឡា ។ល។

**៣២. តើមធ្យោបាយដឹកជញ្ជូនណាខ្លះត្រូវបានហាមឃាត់នៅពេលឃោសនាបោះឆ្នោត?**

មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរដ្ឋដូចជា រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ផ្លាកសញ្ញា រាជការ ឬរដ្ឋ ន.ប ខ.ម និងរាជរដ្ឋាភិបាល ។

**៣៣. តើនរណាខ្លះអាចចូលរួម និងនរណាខ្លះមិនអាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះបេក្ខជន ឬគណបក្សនយោបាយណាមួយ?**

- <u>**អ្នកមានសិទ្ធិចូលរួមគាំទ្រក្នុងសកម្មភាពឃោសនាគ្រប់ម៉ោង**</u> គឺប្រជាពលរដ្ឋខ្មែរទាំងពីរ (០២) ភេទ ។

- <u>**អ្នកមិនមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងការឃោសនាក្នុងអំឡុងម៉ោងធ្វើការ**</u> គឺមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់ លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នរបាលជាតិ និងមន្ត្រីតុលាការ ។ ប៉ុន្តែបន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ អ្នកទាំងនេះអាចចូលរួម គាំទ្រក្នុងសកម្មភាពឃោសនាបោះឆ្នោតបាន តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន និងមិនត្រូវមានអាវុធជាប់នឹងខ្លួនឡើយ ។

**៣៤. តើបញ្ហាអ្វីខ្លះជាការរំលោភក្នុងពេលធ្វើការឃោសនាបោះឆ្នោត ដែលយើងគួរត្រូវកត់សម្គាល់ ?**

- ធ្វើសកម្មភាពឃោសនារំលោភលើកាលបរិច្ឆេទ (មុនថ្ងៃទី២៦ ខែមិថុនា និងក្រោយថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៨) ។
- អំពើហិង្សា ឬការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្ខំធ្វើសម្បថ ឬបង្ខំឱ្យផ្តិត

មេដៃពីគណបក្សនយោបាយ អ្នកមានអំណាច កងកំលាំងប្រដាប់ អាវុធ មេភូមិ អនុប្រធាន ភូមិ និងសមាជិកភូមិ ។

- ការផ្តល់ប្រាក់កាស ឬសម្ភារៈក្នុងគោលបំណងទិញសន្លឹកឆ្នោត ។
- ប្រើសំដីប្រមាថមើលងាយអ្នកបោះឆ្នោត ឬគណបក្សនយោបាយ ឬបេក្ខជន ។
- មានវត្តមានកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ និងអាជ្ញាធរដែនដីគ្រប់ លំដាប់ថ្នាក់ចូលរួមគាំទ្រសកម្មភាពឃោសនាបោះឆ្នោត ក្នុងម៉ោងធ្វើការ ។
- ភាពលំអៀងលើការប្រើប្រាស់ទីសាធារណៈ ។
- អំពើបៀតបៀនរបស់គណបក្សនយោបាយ ឬបេក្ខជនទៅលើគណបក្សនយោបាយ ឬបេក្ខជនផ្សេងទៀត ។
- ការជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជន ។ល ។ និង ។ល ។

## ៣៥. តើភារកិច្ច និងភាតព្វកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយរដ្ឋត្រូវធ្វើដូចម្តេច?

- កាសែត វិទ្យុ និងទូរទស្សន៍របស់រដ្ឋត្រូវផ្សព្វផ្សាយគ្រប់ព័ត៌មានដែលស្នើឡើងដោយ គ.ជ.ប ដោយឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយពីការងារបោះឆ្នោត និងការអប់រំអ្នកបោះឆ្នោត ។

## ៣៦. តើលោកអ្នកត្រូវមានសកម្មភាពអ្វីខ្លះក្នុងពេលឃោសនាបោះឆ្នោត?

- ចូលរួមស្តាប់ការឃោសនារបស់បេក្ខជនតាមរយៈ ការប្រជុំ មីទិញ ការផ្សាយតាមវិទ្យុ និងទូរទស្សន៍
- មើល អានឯកសារឃោសនារបស់គណបក្ស ៖ ខិត្តប័ណ្ណ ផ្ទាំងរូបភាព ទូរទស្សន៍ និងឯកសារផ្សេងៗ
- លើកឡើងពីតំរូវការចាំបាច់ក្នុងឃុំ-សង្កាត់របស់ខ្លួនទៅបេក្ខជន និងគណបក្សនយោបាយនីមួយៗ
- សួរដេញដោលទៅបេក្ខជន និងគណបក្សនយោបាយនីមួយៗអំពីយុទ្ធសាស្ត្រធ្វើ

ការងារតាមការសន្យាដោយជោគជ័យ ថាតើយុទ្ធសាស្ត្រទាំងនោះមានលក្ខណៈប្រាកដនិយម ឬច្បាស់លាស់អាចធ្វើបានដែរឬទេ? ឬគ្រាន់តែនិយាយក្នុងគោលបំណងទាក់ទាញ សន្លឹកឆ្នោតពីអ្នកបោះឆ្នោតតែប៉ុណ្ណោះ? តើមានបានលើកឡើងអំពីការដោះស្រាយបញ្ហា របស់ស្ត្រីដែរឬទេ? តើមានគោលនយោបាយលើកស្ទួយស្ត្រីឱ្យក្លាយជាអ្នកដឹកនាំ សំរេចចិត្តបានកំរិតណា?

- ស្រាវជ្រាវ និងពិភាក្សារកព័ត៌មានបន្ថែមពីបេក្ខជន គណបក្សនយោបាយ ជាមួយអ្នកជិតខាង និងបងប្អូនក្នុងភូមិឃុំ ។

# នៅថ្ងៃបោះឆ្នោត

## ៣៧. តើថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ធ្វើឡើង នៅ ថ្ងៃ ខែ ឆ្នាំណា ?

ថ្ងៃបោះឆ្នោតត្រូវធ្វើឡើងតែមួយថ្ងៃគត់ ថ្ងៃអាទិត្យ ទី២៧ ខែកក្កដា ឆ្នាំ២០០៨ ចាប់ពីម៉ោង ០៧.០០ព្រឹក រហូតដល់ ម៉ោង០៣.០០រសៀល ។

## ៣៨. ទីកន្លែងបោះឆ្នោត

ប្រជាពលរដ្ឋម្នាក់ៗ ត្រូវទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតដែលឈ្មោះរបស់ខ្លួនមាននៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យនោះ (ទៅបោះឆ្នោតតាមលេខកូតការិយាល័យ និងលេខរៀងឈ្មោះរបស់ខ្លួនដែលបានកត់ត្រាទុក) ។

## ៣៩. ដើម្បីបោះឆ្នោតបាន និង ងាយស្រួល តើលោកអ្នកត្រូវធ្វើដូចម្តេច?

១) - ត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ

២) - ត្រូវមានឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន (ឈ្មោះ សញ្ជាតិ អាយុ និងទីលំនៅបច្ចុប្បន្ន)

៣) - ទៅឱ្យទាន់ម៉ោងពី ៧:០០ ដល់ម៉ោង៣:០០

៤) - ស្គាល់លេខកូតការិយាល័យ ទីតាំងការិយាល័យបោះឆ្នោត និងលេខរៀងឈ្មោះ

របស់ខ្លួន

៥) -មិនមានទឹកខ្មៅប្រឡាក់ម្រាមដៃ




**៤០. តើឯកសារបញ្ជាក់អត្តសញ្ញាណអ្វីខ្លះ ដែលលោក អ្នកត្រូវយកទៅជាមួយនៅថ្ងៃបោះឆ្នោត?**

នៅថ្ងៃបោះឆ្នោត លោក អ្នកត្រូវយកឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន និងត្រូវចងចាំនូវលេខកូតការិយាល័យ និងលេខរៀងឈ្មោះរបស់ខ្លួន ដែលមានក្នុងបញ្ជីបោះឆ្នោតផ្លូវការ ឬដែលមាននៅក្នុងប័ណ្ណព័តិមាន។

លោក-អ្នកត្រូវកាន់យកទៅជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ ក្នុងចំណោមឯកសារដូចខាងក្រោម :

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- សៀវភៅគ្រួសារមានបិទរូបថត
- លិខិតបញ្ជាក់របស់មេឃុំ-ចៅសង្កាត់ (តាមទំរង់ .១០១៨. របស់ គ.ជ.ប)
- លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា

- អត្តសញ្ញាប័ណ្ណមន្ត្រីរាជការ, នគរបាល, យោធា
- ឆាយាគណៈមហានិកាយ
- សុទ្ធិប័ត្រគណៈធម្មយុត្តិកនិកាយ

**<u>បញ្ជាក់</u>:** បណ្ណ័បោះឆ្នោតឆ្នាំ១៩៩៣ ឆ្នាំ១៩៩៨ និង ឆ្នាំ២០០២ និងប័ណ្ណពតិមាន អ្នកបោះឆ្នោតមិនត្រូវយកមកប្រើសំរាប់ការបោះឆ្នោតទៀតឡើយ ។

## ៤១. តើប័ណ្ណព័ត៌មានជាអ្វី ?

ប័ណ្ណព័តិមាន មិនមែនជាប័ណ្ណបោះឆ្នោតទេ និងមិនអាចប្រើជំនួសឯកសារបញ្ជាក់អត្តសញ្ញាណសាមីខ្លួនបានឡើយ ។ វាគ្រាន់តែជាឯកសារជំនួយសំរាប់អ្នកបោះឆ្នោតតែប៉ុណ្ណោះ ។ *"ប័ណ្ណព័តិមានអ្នកបោះឆ្នោត និងផ្តល់ព័តិមានស្តីពីកាលបរិច្ឆេទបោះឆ្នោត ទីតាំងការិយាល័យ បោះឆ្នោត លេខការិយាល័យបោះឆ្នោត ឈ្មោះ ភេទ ថ្ងៃខែឆ្នាំ កំណើតអាសយដ្ឋាន និងលេខរៀងឈ្មោះរបស់អ្នកបោះឆ្នោត"* ។

## ៤២. តើអ្នកបោះឆ្នោតចាំបាច់យកប័ណ្ណពត៌មានទៅជាមួយសំរាប់ការបោះឆ្នោតដែរឬទេ?

<u>មិនចាំបាច់ទេ</u> ។ តែលោកអ្នកត្រូវតែចងចាំអំពីទីតាំងកិរិយាល័យ និងលេខកូដការិយាល័យ ដើម្បីងាយស្រួលក្នុងការផ្ទៀងរកឈ្មោះរបស់ខ្លួនលោកអ្នកផង ។ លោក អ្នកត្រូវចាំថាប័ណ្ណពតិមាន អ្នកបោះឆ្នោតគ្រាន់តែ ជាឯកសារសំរាប់ជំរាបអំពីទីតាំង និងលេខកូដការិយាល័យ បោះឆ្នោតរបស់លោកអ្នកតែប៉ុណ្ណោះ គឺមិនមែនជាឯកសារ បញ្ជាក់អត្តសញ្ញាណរបស់លោក អ្នកសំរាប់យកទៅបោះឆ្នោតឡើយ ។

## ៤៣. តើអ្នកបោះឆ្នោតត្រូវមានតួនាទី ភារកិច្ច ដូចម្តេចខ្លះក្នុងថ្ងៃបោះឆ្នោត?

- ប្រជាពលរដ្ឋត្រូវទៅបោះឆ្នោត
- ត្រូវបោះឆ្នោតតាមឆន្ទៈរបស់ខ្លួនទោះបីបេក្ខជន ឬគណបក្សណាមួយបានឱ្យលុយសម្ភារៈ ឱ្យធ្វើសម្បថ ឬបំភិតបំភ័យយ៉ាងណាក៏ដោយ (ការបោះឆ្នោតធ្វើឡើងដោយ<u>សម្ងាត់</u> គ្មាននរណាអាចដឹងបានទេ!) ។
- ជួយពិនិត្យ និងផ្តល់ព័តិមានអំពីភាពមិនប្រក្រតី ក្នុងថ្ងៃបោះឆ្នោតទៅស្ថាប័ន

រៀបចំការបោះឆ្នោត អ្នកសង្កេតការណ៍ជាតិដូចជាខុមហ្វ្រែល (COMFREL) និងអន្តរជាតិ ព្រមទាំងអ្នកសង្កេតការណ៍/និងឬភ្នាក់ងារគណបក្សនយោបាយ ។

## ៤៤. តើអ្វីខ្លះអាចធានាការសម្ងាត់នៃសន្លឹកឆ្នោត ?

- ប្រជាពលរដ្ឋមានសិទ្ធិបដិសេធមិនឆ្លើយចំពោះសំណួរដែលចង់ដឹងថាខ្លួនបោះឆ្នោតឱ្យគណបក្សណាមួយ ឬបេក្ខជនណាមួយ ដោយមានសិទ្ធិរក្សាការសម្ងាត់នេះជាដាច់ខាត ។
- ច្បាប់បោះឆ្នោតក៏បានធានាភាពសម្ងាត់នៃសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតពីជនណាដែលជជីកចង់ដឹង ឬគំរាមកំហែងអ្នកបោះឆ្នោត ឬលួងលោមសួរចង់ដឹង ឬប្រើប្រាស់មធ្យោបាយ ដើម្បីដឹងថា អ្នកបោះឆ្នោតបានបោះឆ្នោតគាំទ្រគណបក្ស ឬ បេក្ខជនណាមួយនោះ ត្រូវមានទោសតាមច្បាប់បោះឆ្នោត ។
- អ្នកបោះឆ្នោតត្រូវមានការជឿជាក់ថា គ្មានជាដាច់ខាតនូវឧបករណ៍ទំនើបការថតរូបតាមកុំព្យូទ័រ ឬតាមផ្កាយរណប ឬ បច្ចេកទេសវិទ្យាសាស្ត្រណាដែលអាចមើលឃើញ អាចដឹងពីការសម្ងាត់នៃសន្លឹកឆ្នោតបានឡើយ ។
- សន្លឹកឆ្នោតដែលត្រូវបាន ប្រើប្រាស់គឺមិនមានការផ្ទៀងផ្ទាត់គល់បញ្ជីជាមួយនឹងសន្លឹកឆ្នោតទេ។ សន្លឹកឆ្នោតមានលក្ខណៈ និងសណ្ឋានដូចគ្នាដោយគ្មានអ្វីជាសញ្ញាសំគាល់ឡើយ ។
- ប្រជាពលរដ្ឋគួរស្វែងយល់ពីការរក្សាការសម្ងាត់នៃសន្លឹកឆ្នោត ។ អ្នកបោះឆ្នោតគូសសន្លឹកឆ្នោតនៅក្នុងបន្ទប់សម្ងាត់ ហើយបត់សន្លឹកឆ្នោតដោយមិនមានអ្នកណាឃើញទេ។ បន្ទាប់មកអ្នកបោះឆ្នោត ទំលាក់សន្លឹកឆ្នោតទៅក្នុងហិបឆ្នោតនៅពេលនោះ សន្លឹកឆ្នោតនឹងលាយឡំគ្នា នៅក្នុងហិបឆ្នោតដោយគ្មានអ្នកណាដឹងថាសន្លឹកឆ្នោតណាមួយជារបស់អ្នកណាឡើយ ។

**ដូចនេះ** សូមលោក អ្នកជឿជាក់ថា ការបោះឆ្នោតជាការសម្ងាត់ គ្មានអ្នកណា ដឹងថាលោក អ្នកសំរេចចិត្តបោះឆ្នោតឱ្យ គណបក្សណា ឬបេក្ខជនណាមួយឡើយ ។ លោកអ្នកនឹងរក្សាការសម្ងាត់របស់ខ្លួនបានជារៀងរហូត ។

**៤៥. តើលោកអ្នកអាចនឹងខកខានការបោះឆ្នោតដែរឬទេបើនៅថ្ងៃបោះឆ្នោតដល់ម៉ោង៣.០០រសៀលទៅហើយ លោក អ្នកនៅតែរង់ចាំក្នុងជួរដដែលនៅខាងក្រៅការិយាល័យបោះឆ្នោត ?**

លោក អ្នកនៅតែអាចបោះឆ្នោតបានដដែល ។ ម៉ោង៣.០០រសៀល មន្ត្រីទទួលបន្ទុកនៅការិយាល័យបោះឆ្នោត នឹងធ្វើការប្រមូលប័ណ្ណបញ្ជាក់អត្តសញ្ញាណរបស់ លោក អ្នក ដែលនៅរង់ចាំក្នុងជួរទាំងអស់ គឺប្រមូលចាប់ពីជួរក្រោយមុន ។ បន្ទាប់មកពួកគេនឹងហៅឈ្មោះលោក អ្នកម្តងម្នាក់ៗឱ្យចូលទៅក្នុងការិយាល័យ ដើម្បីបោះឆ្នោតរហូតទាល់តែអស់ ។

**៤៦. តើលោក អ្នកអាចបោះឆ្នោតបានដែរឬទេ បើលោកអ្នកទៅដល់ ការិយាល័យបោះឆ្នោតយឺត២ ឬ៣នាទី?**

ទេ ! លោក អ្នកមិនអាចបោះឆ្នោតបានទេ។ ជនណាក៏ដោយដែលមកដល់ការិយាល័យបោះឆ្នោតនៅក្រោយ ម៉ោង៣:០០រសៀល ឬមិនបានឈរក្នុងជួរនោះ ពួកគេនឹងមិនមានសិទ្ធិបោះឆ្នោតឡើយ ។

**៤៧. តើលោក អ្នកត្រូវបោះឆ្នោតតាមការសន្យាចំពោះគណបក្សដែលបានផ្តល់ប្រាក់កាសសម្ភារៈឬដឹកជញ្ជូនលោកអ្នកមកកាន់ស្ថានីយ៍បោះឆ្នោត ឬគំរាមកំហែងលោកអ្នកតាមពាក្យសំដី ឬអាកប្បកិរិយាដែរឬទេ?**

**មិនចាំបាច់បោះឆ្នោតឱ្យទេ !** ការបោះឆ្នោត គឺជាការជ្រើសរើសដោយសេរីរបស់លោកអ្នក ដើម្បីគាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដែលលោកអ្នកពេញចិត្ត។ គ្មាននរណាម្នាក់អាចបង្ខំលោកអ្នកឱ្យបោះឆ្នោតឱ្យគណបក្សណាមួយបានឡើយ ។

ទោះបីលោក អ្នកធ្លាប់សន្យាជាមួយគណបក្សណាមួយថានឹងបោះឆ្នោតឱ្យគេក៏ដោយ លោក អ្នកនៅតែមានសិទ្ធិសំរេចចិត្ត ដោយសេរី តាមឆន្ទៈ និងការពេញចិត្តរបស់ខ្លួន គឺមានតែលោក អ្នកម្នាក់គត់ដែលឈរក្នុងបន្ទប់សម្ងាត់បោះឆ្នោត ហើយគ្មាននរណាម្នាក់ដឹងថា លោក អ្នកបោះឆ្នោតឱ្យគណបក្សណាមួយឡើយ ។ សូមចងចាំថា **ការបោះឆ្នោតជាការសម្ងាត់!**

## ៤៨. បើលោក អ្នកជាជនពិការ (ដែលលទ្ធភាពគូសសន្លឹកឆ្នោតដោយខ្លួនឯងបាន តើលោក អ្នកអាចបោះឆ្នោតបានយ៉ាងដូចម្តេច ?

- **ពិតជាអាចបោះឆ្នោតបាន !** លោក អ្នក មានសិទ្ធិជ្រើសរើសអ្នកជំនួយម្នាក់ជានីតិជន ដែលទុកចិត្តបំផុតទៅជាមួយ ឬមានសិទ្ធិសុំជំនួយពីប្រធានការិយាល័យបោះឆ្នោត ។
- នៅពេលដែលប្រធានការិយាល័យបោះឆ្នោត បានចាត់តាំងមនុស្សម្នាក់ឱ្យជួយ ឬនីតិជនទៅជាមួយលោកអ្នក ។ ជននោះនឹងនាំលោក អ្នកទៅបន្ទប់សម្ងាត់ហើយសួរលោកអ្នកតិចៗថា តើលោក អ្នកចង់បោះឱ្យគណបក្សណាមួយ ? អ្នកជំនួយការនោះនឹងជួយលោកអ្នកគូសលើសន្លឹកឆ្នោតត្រង់ឈ្មោះគណបក្ស នយោបាយ ដែលលោក អ្នកមានបំណងបោះឱ្យនោះ និងណែនាំលោក អ្នកឱ្យស៊ក សន្លឹកឆ្នោតចូលក្នុងហិបឆ្នោតផងដែរ ។
- ជំរើសដ៏ល្អបំផុតសំរាប់លោកអ្នកជាជនពិការ ក្នុងការជ្រើសរើសអ្នកជំនួយពេលបោះឆ្នោត គឺគួរយកបងប្អូន មិត្តភ័ក្តិ ឬអ្នកណាដែលលោកអ្នកទុកចិត្តបំផុត ។

## ៤៩. ក្នុងករណីអ្នកបោះឆ្នោតពិការម្រាមចង្អុលដៃស្តាំ តើអ្នកបោះឆ្នោតត្រូវប្រើម្រាមដៃណាដើម្បីជ្រលក់ទឹកខ្មៅ?

- ក្នុងករណីនេះអ្នកបោះឆ្នោតត្រូវប្រើដៃផ្សេងតាមលំដាប់ដូចតទៅ : ម្រាមចង្អុលខ្មោចស្តាំ ឬនាងដៃស្តាំ ឬកូនដៃស្តាំ ឬមេដៃស្តាំ ឬមេដៃឆ្វេង ឬចង្អុលដៃឆ្វេង ឬម្រាមចង្អុលខ្មោចឆ្វេង ឬនាងដៃឆ្វេង ឬកូនដៃឆ្វេង ។ ប្រសិនបើគាត់មិនអាចធ្វើបានតាមការកំណត់ខាងលើ រាល់ការជ្រលក់ ឬលាបផ្នែកណាមួយនៃអវយវៈរបស់គាត់ត្រូវទទួលយកជាការបាន ។

## ៥០. ចំពោះស្ត្រីមេផ្ទះដែលធ្វើការមមាញឹកនៅក្នុងផ្ទះ ហេតុអ្វីត្រូវខ្វល់ខ្វាយអំពីការបោះឆ្នោតនោះ ?

**ត្រូវតែចូលរួមក្នុងការបោះឆ្នោត !**

បងប្អូននារី និងស្ត្រីមេផ្ទះគួរចាប់អារម្មណ៍ថា យើងក៏ជាសមាជិកម្នាក់ក្នុងសង្គម-

ជាតិដែរ ដូច្នេះ យើងត្រូវមានតួនាទីយ៉ាងសំខាន់ចូលរួមក្នុងការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំ ដើម្បីអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែប្រសើរឡើង ។ ដូចនេះ ទោះបីជា បងប្អូននារី និងស្ត្រីមេផ្ទះមានការមមាញឹកច្រើននឹងការងារផ្ទះយ៉ាងណាក៏ដោយ សូមបងប្អូនឆ្លៀតពេលទៅបោះឆ្នោតឱ្យបានទាន់ពេលវេលា ព្រោះការបោះឆ្នោតគឺមានរយៈពេលតែមួយថ្ងៃគត់ យើងមិនត្រូវឱ្យឱកាសដ៏ល្អនេះកន្លងហួសទេ ព្រោះសន្លឹកឆ្នោត របស់លោកស្រី១សន្លឹក មានតម្លៃណាស់សំរាប់អនាគតពួកយើង កូនចៅជំនាន់ក្រោយ និងអនាគតប្រទេសជាតិ ។

## ៥១. បើក្នុងករណីមានធុរៈចាំបាច់ តើយើងអាចឱ្យអ្នកដទៃទៅបោះឆ្នោតជំនួសបានដែរឬទេ ?

***អត់បានទេ !*** លោក អ្នកមិនអាចឱ្យអ្នកដទៃក្រៅពីខ្លួនយើងទៅបោះឆ្នោតជំនួសបានឡើយ ។ អ្នកបោះឆ្នោតម្នាក់មានសិទ្ធិបោះឆ្នោតតែមួយសន្លឹក និងតែមួយដងគត់ក្នុងមួយអាណត្តិ ដោយត្រូវទៅបោះឆ្នោតដោយខ្លួនឯងផ្ទាល់ ។ លោក អ្នកចាំបាច់ណាស់ ត្រូវឆ្លៀតពេលទៅបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ព្រោះថាការបោះឆ្នោតគឺជាជោគវាសនារបស់ភូមិ ឃុំ មណ្ឌល លោក អ្នកទាំងមូល ហើយត្រូវបានគេធ្វើឡើងរៀងរាល់ប្រាំឆ្នាំម្តង ។

## ៥២. តើលោក អ្នកអាចបោះឆ្នោតច្រើនដងបានដែរឬទេ ?

***អត់បានទេ!*** អ្នកបោះឆ្នោតទាំងអស់មានសិទ្ធិបោះឆ្នោតបានតែមួយដងគត់ហើយបានតែមួយសន្លឹកដូចៗគ្នា ។ ជនទាំងឡាយដែលបានបោះឆ្នោត ហើយមន្ត្រីការិយាល័យបោះឆ្នោតនឹងជ្រលក់ចង្អុលដៃស្តាំលោកអ្នក (កន្លែងផ្សេងទៀត បើជាជនពិការ) ក្នុងទឹកខ្មៅលុបលាងមិនជ្រះ ។ ប្រសិនបើមានស្នាមទឹកខ្មៅនេះនៅលើម្រាមដៃលោកអ្នក ប្រធានការិយាល័យនឹងប្រាប់ទៅភ្នាក់ងារគណបក្ស ឬអ្នកសង្កេតការណ៍ ដើម្បីចំណាំ ហើយនឹងសួរនាំលោក អ្នកឱ្យពន្យល់អំពីមូលហេតុ ដែលមានស្នាមទឹកថ្នាំ ប្រឡាក់លើម្រាមដៃលោកអ្នក ។ ប្រសិនបើការពន្យល់របស់លោកអ្នកមិនសមហេតុផលទេនោះប្រធាន ការិយាល័យនឹងសន្និដ្ឋានថាលោកអ្នកព្យាយាមបោះឆ្នោត២ដង ។

ឯកសារបញ្ជាក់ពី អត្តសញ្ញាណរបស់លោកអ្នកនឹងត្រូវដកហូត ហើយបញ្ជូនទៅគណៈកម្មការ ឃុំ-សង្កាត់រៀបចំការបោះឆ្នោត ដើម្បីតាមដានបន្តទៀត ។

## ៥៣. បើលោកអ្នកជាជាងជួសជុលគ្រឿងម៉ាស៊ីន យន្តហោះ រថយន្ត ម៉ូតូ តើត្រូវលាងសំអាតម្រាមដៃរបស់ខ្លួនឬទេ មុនពេលទៅបោះឆ្នោត?

*ត្រូវតែលាងដៃ (ម្រាមដៃ ស្តាំ-ឆ្វេង) ឱ្យបានស្អាត!* ដើម្បីងាយស្រួលបោះឆ្នោត និងចំណេញពេលវេលា ។ ព្រោះថា បើម្រាមដៃលោកអ្នកមានប្រឡាក់ប្រេងម៉ាស៊ីន ដែលមាន**ពណ៌ក្រម៉ៅស្រដៀងនឹងស្នាមទឹកខ្មៅ**សំរាប់ឱ្យអ្នកបោះឆ្នោតជ្រលក់ចង្អុល ដៃនោះប្រធានការិយាល័យបោះឆ្នោត មន្ត្រីផ្សេងៗទៀត ភ្នាក់ងារគណបក្ស និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិនឹងចាប់ផ្តើម សង្ស័យមកលើលោកអ្នក ហើយប្រធានការិយាល័យបោះឆ្នោតនឹងសួរនាំលោកអ្នកឱ្យពន្យល់អំពីមូលហេតុដែលមានស្នាមថ្នាំខ្មៅប្រឡាក់លើម្រាមដៃលោកអ្នក ។ បើការពន្យល់របស់លោកអ្នកសមហេតុផល ប្រធានការិយាល័យ បោះឆ្នោតនឹងអនុញ្ញាតឱ្យលោក អ្នកបោះឆ្នោត ប៉ុន្តែបើមិនសមហេតុផលទេ លោកអ្នក នឹងមិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ ។ ដូច្នេះលោកអ្នកត្រូវតែលាងសំអាតម្រាមដៃ ឱ្យបានស្អាតមុនពេលចេញទៅបោះឆ្នោត!

## ៥៤. ករណី ៣ ដែលលោក អ្នកមិនអាចបោះឆ្នោតបាន

សូមចងចាំករណីទាំង ៣ នេះគឺ :

១- លោក អ្នកមិនបានចុះឈ្មោះបោះឆ្នោតជាមុន និងគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ។

២- លោកអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតហើយ ប៉ុន្តែលោកអ្នកមិនមានឯកសារបញ្ជាក់អំពីអត្តសញ្ញាណបង្ហាញមន្ត្រី ការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។

៣-លោក អ្នកមានស្នាមប្រឡាក់ទឹកខ្មៅលើម្រាមដៃ ។

## ៥៥. នៅថ្ងៃបោះឆ្នោត បើលោកអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មានឯកសារ បញ្ជាក់អត្តសញ្ញាណ ប៉ុន្តែត្រូវគេរារាំងមិនឱ្យបោះឆ្នោត ឬរកឈ្មោះ មិនឃើញ តើត្រូវធ្វើដូចម្តេច?

- ករណីនេះ លោកអ្នកត្រូវរាយការណ៍ភ្លាមទៅប្រធានការិយាល័យបោះឆ្នោត ឬអ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយ ។

- ករណីលោកអ្នកមិនត្រូវអនុញ្ញាតឱ្យបោះឆ្នោត លោកអ្នកត្រូវធ្វើពាក្យបណ្ដឹង លើទំរង់ ១២០២ ។

## ៥៦. តើលោកអ្នកនឹងមិនទៅបោះឆ្នោតមែនទេ នៅពេលដែលមិនឃើញមានអ្វីប្រែប្រួលជីវភាពក្រោយពេលបោះឆ្នោត ?

**សូមកុំអស់សង្ឃឹម!** សូមប្រែក្លាយការអស់សង្ឃឹមទៅជាការចូលរួមយ៉ាងសកម្មក្នុងការបោះឆ្នោត។ សូមលោកអ្នកជឿជាក់ថា គេអាចយកតំណក់ទឹកទៅបំបែកផ្ទាំងសិលាដ៏ធំមួយបាន ដូចនេះការទៅបោះឆ្នោតជ្រើសរើសតំណាងរបស់លោកអ្នកតាមការពេញចិត្តមានសារៈសំខាន់ណាស់ ដើម្បីជាកំលាំងចលករជំរុញឱ្យអ្នកជាប់ឆ្នោតទទួលខុសត្រូវ និងដោះស្រាយបញ្ហាទាំងឡាយក្នុងសង្គមជាបន្តបន្ទាប់ ដើម្បីអនាគតពួកយើង កូនចៅជំនាន់ក្រោយ និងប្រទេសជាតិយើងឱ្យមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ និងមានការរីកចំរើន ។

## ៥៧. តើលោក អ្នកត្រូវធ្វើដូចម្ដេចនៅពេលដែលគូសច្រឡំលើសន្លឹកឆ្នោត ?

- បើសិនលោកអ្នកគូសច្រឡំលើសន្លឹកឆ្នោតដោយអចេតនា ដែលមន្ត្រីការិយាល័យប្រគល់ឱ្យលោកអ្នកអាចសុំប្ដូរសន្លឹកឆ្នោតផ្សេងទៀតពីប្រធានការិយាល័យបោះឆ្នោតបាន។
- លោកអ្នកត្រូវបត់សន្លឹកឆ្នោតដែលខុសនោះឱ្យបាន២ដងដើម្បីកុំឱ្យគេមើលឃើញរួចហុចឱ្យប្រធានការិយាល័យបោះឆ្នោត ។
- ប្រធានការិយាល័យបោះឆ្នោតនឹងបង្គាប់ទៅអនុប្រធានឱ្យផ្ដល់សន្លឹកឆ្នោតមួយផ្សេងទៀតឱ្យលោកអ្នក ។

**សំគាល់:** លោក អ្នកអាចទទួលសន្លឹកឆ្នោតលើកទី២នេះបានតែម្ដងគត់ ។

## ៥៨. តើសន្លឹកឆ្នោតប្រភេទណាខ្លះដែលមិនអាចយកជាការបាន ?

សន្លឹកឆ្នោតដែលត្រូវទុកជាមោឃៈ ឬមិនបានការ :

- ដែលពុំមែនជាសន្លឹកឆ្នោតផ្លូវការ ឬ
- ពុំមែនជាសន្លឹកឆ្នោតដែលផ្ដល់ឱ្យដោយការិយាល័យបោះឆ្នោត ឬ
- ដែលគ្មានគូស ឬមានគំនូស តែគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតពុំអាច

សន្និដ្ឋានបានថា លោកអ្នកបោះឱ្យ គណបក្សនយោបាយណាមួយ ឬ

- គូសឱ្យបញ្ជីបេក្ខជនលើសពីមួយ ឬ
- មានសញ្ញាដែលនាំឱ្យគេស្គាល់អ្នកបោះឆ្នោត ឬ
- ដែលមានរហែក ឬខូច ឬ
- ដែលគ្មានត្រាសម្ងាត់ជាផ្លូវការ ។

# ការរាប់សន្លឹកឆ្នោត




## ៥៩. តើការរាប់សន្លឹកឆ្នោតធ្វើឡើងនៅថ្ងៃណា ? ពេលណា ?កន្លែងណា ?

- ការរាប់សន្លឹកឆ្នោតធ្វើនៅ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ បន្ទាប់ពីបិទការបោះឆ្នោត ។
- ការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅការិយាល័យបោះឆ្នោតតែម្តង (ការិយាល័យបោះឆ្នោត នឹងក្លាយជាការិយាល័យរាប់សន្លឹកឆ្នោត) បន្ទាប់ពីបិទការបោះឆ្នោត និងធ្វើកំណត់ ហេតុនៃការបោះឆ្នោតរួចលើកលែងតែការិយាល័យបោះឆ្នោតណាដែល

មិនអាចរាប់សន្លឹក ឆ្នោតនៅការិយាល័យរបស់ខ្លួនបានដោយសារករណីប្រធានស័ក្តិ ឬអសន្តិសុខ ហើយដែល គ.ជ.ប សម្រេចឱ្យ គឃ/សប ចាត់ចែងរាប់សន្លឹកឆ្នោតនៅទីស្នាក់ការគឃ/សប ឬនៅ កន្លែងណាមួយដែលមានសុវត្ថិភាព។

**៦០. តើគេរាប់សន្លឹកឆ្នោតដែលមានតម្លាភាព ត្រូវធ្វើយ៉ាងដូចម្តេច ?**

សន្លឹកឆ្នោតត្រូវរាប់ទៅតាមវិធីមួយដែលអាចឮ និងមើលឃើញច្បាស់នូវគំនូសនៃការបោះឆ្នោតទាំងអស់ ដោយមាន ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឯករាជ្យជាអ្នកតាមដាន និងផ្ទៀងផ្ទាត់ ។

**៦១. តើនរណាជាអ្នករាប់ និងទទួលខុសត្រូវលើសន្លឹកឆ្នោតនៅពេលរាប់ ?**

គឺមន្ត្រីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ ក្លាយជាមន្ត្រីរាប់សន្លឹកឆ្នោតដែលជាអ្នកទទួលខុសត្រូវក្នុង ការិយាល័យរាប់សន្លឹកឆ្នោតរបស់ខ្លួន ។

# ទោសប្បញ្ញត្តិ និងបណ្តឹង

**៦២. តើសកម្មភាពខុសច្បាប់បោះឆ្នោតខាងក្រោមនេះ ត្រូវផ្តន្ទាទោសយ៉ាងដូចម្តេច ? (*តើសកម្មភាពខុសច្បាប់ណាខ្លះ ដែលចាត់ទុកថាបំពានច្បាប់បោះឆ្នោត ឬជាបទល្មើសបោះឆ្នោត*)**

សកម្មភាពខុសច្បាប់រួមមាន :

- ទិញសន្លឹកឆ្នោតដោយប្រាក់កាស ឬសំភារៈ។
- ការគំរាមកំហែង ការលួងលោម ឬសួរដេញដោលពីគណបក្សដែលប្រជាពលរដ្ឋបោះឆ្នោតឱ្យ ។
- បង្ខំឱ្យធ្វើសម្បថបោះឆ្នោតឱ្យគណបក្ស នយោបាយរបស់ខ្លួន ឬគណបក្សនយោបាយណាមួយដែលខ្លួនពេញចិត្ត។
- ប្រើកំលាំង ឬអំពើហិង្សា ឬបំភិតបំភ័យមិនឱ្យប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋដែលមានសិទ្ធិបោះ

ឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

- ញុះញង់អ្នកគាំទ្រឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ ។
- ប្រើកម្លាំង ឬអំពើហិង្សាដើម្បីរារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន។
- រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់ ។
- ប្រើកម្លាំង ឬអំពើហិង្សា ឬបំភិតបំភ័យ ប្រើពាក្យសំដីប្រមាថមើលងាយ ធ្វើឱ្យមានការភ័យខ្លាចការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន ។
- លំអៀង និង មិនស្មោះត្រង់ក្នុងការអនុវត្តន៍អំណាច មុខងារ និងភារកិច្ច ។
- យកអាវុធជាតិផ្ទុះដោយគ្មានការអនុញ្ញាតចូលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។
- មានចេតនាធ្វើឱ្យរបើកហិបឆ្នោត ដាច់រហែក ឬរបូតសោឃ្លុំ ... ។
- បន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬ ប្រើល្បិចដើម្បីលួចបន្លំលទ្ធផលនៃការបោះឆ្នោត
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន ។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត ។

## ៦៣. តើទណ្ឌកម្មចំពោះបទល្មើសនឹងច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប មានដូចម្តេចខ្លះ?

ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតទោសប្បញ្ញត្តិនៃច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ដែលនឹងអនុវត្តចំពោះបទល្មើសទាក់ទងនឹងការបោះឆ្នោតទៅតាមករណីនីមួយៗមានកំរិតដូចខាងក្រោម :

- ការព្រមាន

- ការដាក់ឱ្យទំនេរគ្មានបៀវត្សរ៍
- ការដាក់វិន័យរដ្ឋបាល
- ការបញ្ឈប់ពីការងារ
- ការបណ្តេញចេញពីការងារ ឬមុខតំណែង
- ការដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះបោះឆ្នោត
- ការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត
- ការលុបបេក្ខភាពរបស់សាមីខ្លួន ឬការលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ
- ការពិន័យជាប្រាក់ ដែលមានចំនួនយ៉ាងតិចចន្លោះពី ប្រាំលាន (៥ 000 000) រហូតដល់ ហាសិបលាន (៥0 000 000) រៀល ទៅតាមករណីនីមួយៗ ។ល។

## ៦៤. តើប្រជាពលរដ្ឋមានសិទ្ធិប្តឹងទៅខាងណា នៅពេលបានឃើញ ជនណាមួយ ប្រព្រឹត្តល្មើសច្បាប់បោះឆ្នោត ?

**ក- <u>ជនល្មើសដែលមិនមែនជាមន្ត្រីបោះឆ្នោត</u> :** ជនគ្រប់រូប តំណាង ឬគណបក្សនយោបាយដែលមានប្រយោជន៍ (ម្ចាស់បណ្តឹង) ត្រូវប្តឹងទៅអាជ្ញាធររៀបចំការបោះឆ្នោតមានសមត្ថកិច្ច តាមថានុក្រមតាមលំដាប់ពីទាបទៅខ្ពស់មានជាអាទិ៍ **គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត** (គកប/គករ) **គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត** (គឃ/សប) **គណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោត** (គខ/កប) **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (គ.ជ.ប) ក្រុមប្រឹក្សាធម្មនុញ្ញ និងស្ថាប័នតុលាការ ។

- **បណ្តឹងនាដំណាក់ការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត :** ក្នុងរយៈពេល *៣ថ្ងៃ* យ៉ាងយូរបំផុត បន្ទាប់ពីបដិសេធដោយស្មៀន ម្ចាស់បណ្តឹងត្រូវប្តឹងទៅ កបឃ/ស។ ប្រសិនមិនសុខចិត្ត ក្នុងរយៈពេល *៥ថ្ងៃ* យ៉ាងយូរ បំផុត

បន្ទាប់ពី ថ្ងៃទទួលបានលិខិតបដិសេធ គាត់អាចប្តឹងបន្តទៅ គ.ជ.ប ។ បើនៅតែមិនយល់ព្រមទៀត ក្នុងរយៈពេល *៥ថ្ងៃ* យ៉ាងយូរបំផុត គាត់អាចប្តឹងបន្តទៅក្រុមប្រឹក្សាធម្មនុញ្ញ។( ម្ចាស់បណ្តឹង⇨ កបឃ/ស⇨ គ.ជ.ប⇨ ទៅក្រុមប្រឹក្សាធម្មនុញ្ញ )

- **បណ្តឹងនាដំណាក់កាលនៃការនៃការបិទផ្សាយបញ្ជីតំបូង :** មានយន្តការដូចការប្តឹងនាដំណាក់កាលខាងលើនេះដែរ ខុសប្លែកតែរយៈពេលនៃការដាក់ពាក្យបណ្តឹងនីមួយៗប៉ុណ្ណោះ ដោយត្រូវកំណត់មកត្រឹម *៥ថ្ងៃ* យ៉ាងយូរបំផុតវិញ។
- **បណ្តឹងនាដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ :** បេក្ខជន ឬគណបក្សនយោបាយ ( ម្ចាស់បណ្តឹង) ដែលត្រូវបានបដិសេធដោយ គ.ជ.ប ក្នុងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះមានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលយ៉ាងយូរបំផុត *៥ថ្ងៃ* ។ ( ម្ចាស់បណ្តឹង ⇨ ក្រុមប្រឹក្សាធម្មនុញ្ញ )
- **បណ្តឹងនាដំណាក់កាលឃោសនាបោះឆ្នោត :** ក្នុងរយៈពេល *៣ថ្ងៃ* យ៉ាងយូរបន្ទាប់ពីថ្ងៃកើតហេតុ ម្ចាស់បណ្តឹងត្រូវប្តឹងទៅ គឃ/សប ។ករណីមិនសុខចិត្តក្នុងរយៈពេល *៣ថ្ងៃ* យ៉ាងយូរបំផុតបន្ទាប់ពីថ្ងៃសំរេចមិនសះជានៃកំណត់ហេតុ ផ្សះផ្សារម្ចាស់បណ្តឹង អាចប្តឹងបន្តទៅ គខ/កប ។ បើនៅតែមិនសុខចិត្ត ក្នុងរយៈពេល *៣ថ្ងៃ* យ៉ាងយូរបន្ទាប់ពី ថ្ងៃទទួល បានសេចក្តីសំរេចរបស់ គខ/កប ម្ចាស់បណ្តឹងអាចប្តឹងទៀតទៅ គ.ជ.ប ។ បើនៅតែមិនសុខចិត្តទៀត ក្នុងរយៈពេល *៧២ម៉ោង* យ៉ាងយូរបន្ទាប់ពីទទួលបានសេចក្តី សំរេចរបស់ គ.ជ.ប ម្ចាស់បណ្តឹងអាចប្តឹងទៀតទៅក្រុមប្រឹក្សាធម្មនុញ្ញ។

( ម្ចាស់បណ្តឹង ⇨ គឃ/សប ⇨ គខ/កប⇨ គ.ជ.ប⇨ ក្រុមប្រឹក្សាធម្មនុញ្ញ ) ។

- <u>បណ្តឹងនាដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត</u> : ម្ចាស់បណ្តឹងត្រូវប្តឹងផ្ទាល់មាត់ភ្លាមទៅប្រធានគកប/គករ ។បើមិនសុខចិត្តម្ចាស់បណ្តឹងត្រូវប្តឹងតាមទម្រង់ ១២០២ ទៅ គឃ/សប យ៉ាងយូរបំផុតត្រឹមម៉ោង *១១:៣០នាទី នៃ ថ្ងៃ*

*បន្ទាប់ពីថ្ងៃបោះឆ្នោត* ( ត្រឹមម៉ោង១១:៣០នៃថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០៨) ។ ករណីមិនសុខចិត្តក្នុងរយៈ ពេល *២ថ្ងៃ* យ៉ាងយូរបន្ទាប់ពីថ្ងៃចេញសេចក្តីសំរេច ម្ចាស់បណ្តឹង អាចប្តឹងបន្តទៅ គខ/កប ។ បើនៅតែមិនសុខចិត្ត ក្នុងរយៈ ពេល *២ថ្ងៃ* យ៉ាងយូរបន្ទាប់ពី ថ្ងៃចេញសេចក្តីសំរេច ម្ចាស់បណ្តឹងអាចប្តឹងទៀតទៅ គ.ជ.ប ។

( ម្ចាស់បណ្តឹង ⇨ ( គកប/គករ) ⇨ ( គឃ/សប) ⇨ ( គខ/កប ) ⇨ ( គ.ជ.ប ) ) ។

- <u>បណ្តឹងនាដំណាក់កាលនៃការប្រកាសលទ្ធផលបណ្តោះអាសន្ន :</u> ករណីនេះបន្ទាប់ពីប្រកាសលទ្ធផលបណ្តោះអាសន្ន ក្នុងរយៈ ពេល *៧២ម៉ោង*យ៉ាងយូរ ម្ចាស់បណ្តឹង អាចប្តឹងទៅ គ.ជ.ប ហើយបើមិនសុខចិត្ត អាចប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល៧២ម៉ោងយ៉ាងយូរ ឬអាចប្តឹងបដិសេធដោយផ្ទាល់ទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញតែម្តងក៏បាន ។

( ម្ចាស់បណ្តឹង ⇨ គ.ជ.ប ⇨ ក្រុមប្រឹក្សាធម្មនុញ្ញ )

( ម្ចាស់បណ្តឹង ⇨ ក្រុមប្រឹក្សាធម្មនុញ្ញ )

## ៩. <u>ជនល្មើសដែលជាមន្រ្តី ឬសមាជិករបស់អាជ្ញាធររៀបចំការបោះឆ្នោត</u>

ជនណាក៏ដោយមានសិទ្ធិប្តឹង នូវកំហុសរបស់មន្រ្តីរៀបចំការបោះឆ្នោតនៅចំពោះមុខអាជ្ញាធររៀបចំការបោះឆ្នោត ***<u>ថ្នាក់លើមួយថ្នាក់</u>*** ( ឧ: បើឃើញមន្ត្រីការិយាល័យបោះឆ្នោត ឬរាប់សន្លឹកឆ្នោតធ្វើខុសត្រូវប្តឹងទៅ <u>គណៈកម្មការឃុំ/សង្កាត់ រៀបចំការបោះឆ្នោត( គឃ/សប)</u> ។ បើគឃ/សប ធ្វើខុសត្រូវប្តឹងទៅ<u>គណៈកម្មការខេត្ត/ក្រុងរៀបចំការបោះឆ្នោត ( គខ/កប)</u> ។ បើគខ/កបធ្វើខុស ត្រូវប្តឹងទៅ <u>គ.ជ.ប</u> ។ បើមន្ត្រីនៅ ទីស្តីការ គ.ជ.បធ្វើខុសត្រូវប្តឹងទៅប្រធាន គ.ជ.ប ។ បើ គ.ជ.ប ធ្វើខុសត្រូវ ប្តឹងទៅ<u>រដ្ឋសភា</u> កំណត់រយៈពេល៣ថ្ងៃយ៉ាងយូរបន្ទាប់ពីពេលកើតហេតុ លើកលែងតែកាល បរិច្ឆេទកំណត់ ផ្សេងពីនេះក្នុងច្បាប់បោះឆ្នោត ។ តែកាលបរិច្ឆេទកំណត់ ផ្សេងពីនេះក្នុង ច្បាប់បោះឆ្នោត ។

# យេនឌ័រ និងកូតាជាតំណាងអ្នកបោះឆ្នោត

## ៦៥. តើយេនឌ័រមានន័យយ៉ាងដូចម្តេច ?

សំដៅទៅលើភាពខុសគ្នា រវាងបុរស និងស្ត្រីដែលកំណត់ដោយសង្គម ហើយដែលគេបានរៀនសូត្រ និងមានការប្រែប្រួល ពីពេលមួយទៅពេលមួយ។ យេនឌ័រមានការផ្លាស់ប្តូរយ៉ាងទូលំទូលាយរវាងតួនាទីបុរស និងស្ត្រីទៅតាមវប្បធម៌នៅក្នុងសង្គម និងរវាងវប្បធម៌ មួយទៅវប្បធម៌មួយទៀត។

*"យេនឌ័រ"* គឺជាគោលគំនិតផ្អែកសេដ្ឋកិច្ចសង្គមក្នុងការធ្វើវិភាគលើតួនាទីទទួលខុសត្រូវ ឧបសគ្គ និង តម្រូវការរបស់បុរស និងស្ត្រីនៅគ្រប់បរិបទទាំងអស់។ ដោយសារ *"យេនឌ័រ"* ត្រូវបានបង្កើតឡើងដោយសង្គម ទើបការកំណត់អំពីតួនាទី តម្រូវការ អាទិភាព និងសកម្មភាពរបស់ស្ត្រីមានទំនាក់ទំនងនឹងបរិបទជាក់ស្តែងនៃវប្បធម៌ សាសនា និងសេដ្ឋកិច្ចសង្គម។



## ៦៦. ដូចម្តេចដែលហៅថាសមធម៌យេនឌ័រ ?

សមធម៌យេនឌ័រ គឺជាដំណើរការនៃភាពយុត្តិធម៌ចំពោះស្ត្រី និងបុរសទាក់ទងនឹងសិទ្ធិទទួលបានផលប្រយោជន៍ តួនាទី ការទទួលខុសត្រូវ និងឱកាស ។ ដើម្បីធានានូវភាពយុត្តិធម៌ ជាញឹកញាប់គេត្រូវមានវិធានការសមស្រប ដើម្បីដាក់ជំនួសឱ្យការបាត់បង់ឱកាស ជាប្រវត្តិសាស្ត្រ ដែលរារាំងស្ត្រី ឬបុរសមិនឱ្យធ្វើសកម្មភាពស្មើគ្នាគ្រប់វិស័យក្នុងសង្គម ។

## ៦៧. ដូចម្តេចដែលហៅថាសមភាពយេនឌ័រ ?

- សមភាពយេនឌ័រ ឬសមភាពរវាងបុរស និងស្ត្រី មានន័យថា ស្ត្រី និងបុរសមានលក្ខខណ្ឌស្មើៗគ្នា ដើម្បីទទួលបាននូវសិទ្ធិមនុស្សរបស់ខ្លួនឱ្យបានពេញលេញ ដើម្បីរួមចំណែក និងទទួលផលប្រយោជន៍ពីការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចសង្គមការងារវប្បធម៌ និងនយោបាយ ។
- សមភាពយេនឌ័រ គឺជាការឱ្យតំលៃស្មើគ្នាដោយសង្គមទៅលើភាពដូចគ្នា និងភាពខុសគ្នារវាងបុរស និងស្ត្រី និងតួនាទីរបស់ពួកគេ ។
- សមភាពយេនឌ័រ គឺផ្អែកទៅលើភាពជាដៃគូពេញលេញរបស់ស្ត្រី និងបុរសនៅក្នុងគ្រួសារ សហគមន៍ និងសង្គមរបស់ពួកគេ។ សមភាពយេនឌ័រ ចាប់ផ្តើមពីការឱ្យតំលៃស្មើគ្នាដល់កុមារី និងកុមារា ។

## ៦៨. តើយេនឌ័រមានសារៈសំខាន់អ្វីខ្លះ ?

ស្ត្រី និងបុរសជាដៃគូនឹងគ្នាក្នុងការអភិវឌ្ឍប្រទេសជាតិ មានសមភាពយេនឌ័រ គឺមានន័យថា ការចូលរួមរបស់ស្ត្រី និងបុរសមានភាពស្មើគ្នាទាំងការងារក្នុងសង្គម និងនៅផ្ទះ។ មានសមធម៌យេនឌ័រមានន័យថា ការប្រព្រឹត្តចំពោះភេទទាំងពីរគឺដូចគ្នា។ ក្នុងន័យនេះ គឺសំដៅទៅលើការឱ្យតំលៃលើគុណភាពការងារ ការផ្តល់ឱកាស និងការទទួលផលប្រយោជន៍ ។

នៅពេលដែលគោលការណ៍ទាំងពីរនេះត្រូវបានគេគោរព និងអនុវត្តដោយពេញលេញនោះ ការរើសអើងទៅលើស្ត្រីត្រូវបានលុបបំបាត់ចោល ។ ជាលទ្ធផល អំពើហិង្សា

ដែលកើតមានទៅលើស្ត្រី អាចត្រូវបានដោះស្រាយ និយាយឱ្យខ្លីទៅ គឺមានការគោរពសិទ្ធិគ្នាទៅវិញទៅមករវាងបុរស និងស្ត្រី នៅពេលដែលភេទទាំង២នេះ មានតំលៃស្មើគ្នា នាំឱ្យកាត់បន្ថយនូវបញ្ហាសង្គមផ្សេងៗទៀត ។

## ៦៩. តើតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រមានអ្វីខ្លះ ?

តំរូវការយេនឌ័រជាយុទ្ធសាស្ត្រទាក់ទងទៅនឹងឋានៈ តួនាទីរបស់ស្ត្រី និងទំនាក់ទំនងរបស់ស្ត្រីនៅក្នុងសង្គម ។ តម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ ទាក់ទងទៅនឹងការជ្រើសរើស ដើម្បីគ្រប់គ្រងលើធនធាន និងផលប្រយោជន៏ផ្សេងៗ ឬទាក់ទងទៅនឹងការរៀបចំឡើងវិញនូវសមាសភាពគណៈកម្មការអភិវឌ្ឍន៏ភូមិ ដើម្បីបញ្ចូលស្ត្រី និងបុរសឱ្យមានចំនួនស្មើ ។ ដើម្បីដោះស្រាយតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ ចាំបាច់ណាស់ត្រូវធ្វើការផ្លាស់ប្តូរប្រពន្ធ័ ដោយមានការធ្វើអន្តរាគមន៏ឱ្យបានសមស្រប ។

ការដោះស្រាយតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ និងការកែលំអតួនាទីរបស់ស្ត្រីឱ្យបានប្រសើរឡើង អាចសំរេចបានតាមរយៈ :

- ការបង្កើត ឬ កែប្រែគោលនយោបាយសំរាប់កែលំអឋានៈ និង តួនាទីរបស់ស្ត្រី
- លុបបំបាត់នូវរាល់ការរើសអើងប្រឆាំងនឹងស្ត្រី និង កុមារី
- កំណត់គោលការណ៏សមធម៌ សមភាពយេនឌ័រ ដែលអាចជួយដល់ស្ត្រី និងកុមារីមានឱកាសស្មើនឹងបុរស និងកុមារា ក្នុងឱកាសទទួលការងារ ការបណ្តុះបណ្តាល ការអប់រំការធ្វើសេចក្តីសំរេច ប្រាក់បៀវត្សស្មើគ្នាចំពោះការងារដូចគ្នា សិទ្ធិកាន់កាប់ដីធ្លី និងទ្រព្យសម្បត្តិ សិទ្ធិសេរីភាពក្នុងការជ្រើសរើស ការផ្តល់ កំណើតកូន សិទ្ធិគ្រប់គ្រងលើធនធានផលកំរៃផ្សេងៗ និងការចូលរួមក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។
- ការកាត់បន្ថយភាពទន់ខ្សោយដែលទោរទន់ទៅរកអំពើហិង្សា និង ការកេងប្រវ័ញ្ច (ជួញដូរផ្លូវភេទ និង ស្ថានភាពរបស់ស្ត្រីមេម៉ាយ) ។
- សន្តិសុខច្រើនឡើងថែមទៀតសំរាប់សេដ្ឋកិច្ច ឯករាជ្យភាព ការផ្តល់ជំរើស និង ឱកាស ។

- ការចែករំលែកភារកិច្ច ទទួលខុសត្រូវសំរាប់ការងារមិនបានកំរៃ
- ស្ត្រីត្រូវមានសេចក្តីទុកចិត្តលើខ្លួនឯងកាន់តែខ្លាំង
- បង្កើនអំណាចផ្នែកនយោបាយ និងការចូលរួមនៅក្នុងការធ្វើសេចក្តីសំរេចចិត្ត
- អង្គការស្ត្រីកាន់តែលេចធ្លោឡើង និងមានប្រសិទ្ធភាពកាន់តែច្រើនឡើង
- បង្កើនការយល់ដឹងជាសាធារណៈ ស្តីពីបញ្ហារបស់ស្ត្រី និងសារៈសំខាន់ ស្ត្រីចូលរួមជាតំណាងអ្នកបោះឆ្នោត ។

**៧០. តើប្រព័ន្ធកូតាយេនឌ័រសំរាប់តំណាងអ្នកបោះឆ្នោតមានន័យដូចម្តេច ?**

គំនិតសំខាន់នៃប្រពន្ធ័កូតា គឺដើម្បីជ្រើសរើសស្ត្រីឱ្យកាន់តំណែងនយោបាយ និងដើម្បីធានាថាស្ត្រីមិនមែនជាអ្នកដែលត្រូវបានគេជ្រើសរើសតិចតួចនៅក្នុងជីវិតនយោបាយ។

ប្រព័ន្ធកូតាយេនឌ័រ សំដៅធានាឱ្យបានថា ស្ត្រី ឬបុរស (ជាពិសេសស្ត្រី)ចូលរួមក្នុងគ្រប់ទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច សង្គម ក៏រិត ៥០% ទល់នឹង ៥០% ទោះបីនៅប្រទេសមួយចំនួន កូតានេះ ត្រូវបានកំណត់ត្រឹម ៣០% ឬ ៤០%ក៏ដោយ ។

**ការអនុវត្តប្រពន្ធ័កូតាមិនផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ !!**

**ការវិវត្តថ្មីមួយទៀត គឺកូតាទ្វេ**

កូតាទ្វេ ត្រូវបានប្រើនៅក្នុងប្រពន្ធ័កូតា គឺមិនត្រឹមតែកំណត់ភាគរយជាក់លាក់មួយរបស់ស្ត្រីនៅក្នុងបញ្ជីឈរឈ្មោះបោះឆ្នោតប៉ុណ្ណោះទេ ថែមទាំងបង្គារឱ្យបានថា បេក្ខនារីមិនត្រូវបានគេដាក់ឈ្មោះនៅខាងក្រោម១នៃបញ្ជីបេក្ខជន ។ មានន័យថា បេក្ខនារីត្រូវបានគេដាក់ឈ្មោះនៅខាងលើនៃបញ្ជីបេក្ខជន ឬក៏ត្រូវបានដាក់ឈ្មោះឆ្លាស់គ្នារវាងបេក្ខជន និងបេក្ខនារីនៅខាងលើនៃបញ្ជីបេក្ខជនឈរឈ្មោះយ៉ាងហោច ៣០%ទៅ៤០% ។

**៧១. តើប្រព័ន្ធកូតាយេនឌ័រមានសារៈសំខាន់អ្វីខ្លះ ?**

**មានសារៈសំខាន់ណាស់!** ព្រោះវាជួយឱ្យមានការលើកទឹកចិត្តដល់ស្ត្រីក្នុងការចូលរួមក្នុងកិច្ចការសង្គម ក៏ដូចជានយោបាយ ហើយមានប្រយោជន៏ថែមទៀតសំរាប់ប្រទេសដែលមានវិសមភាពយេនឌ័រដូចជាប្រទេសកម្ពុជាពីព្រោះប្រព័ន្ធនេះជួយជំរុញឱ្យរដ្ឋាភិបាលយកចិត្តទុកដាក់ដល់ស្ត្រី និងជួយស្ត្រីឱ្យមានឱកាសក្លាយជាអ្នកដឹកនាំនៅថ្នាក់ជាតិ និង

ថ្នាក់មូលដ្ឋាន ។

- ការប្រើប្រាស់ប្រព័ន្ធកូតា គឺកាត់បន្ថយនូវគម្លាតរវាងបុរស និងស្ត្រីក្នុងការធ្វើសេចក្ដីសំរេចចិត្ត ។
- ប្រព័ន្ធកូតានេះ គឺជាគន្លឹះសំរាប់ជំរុញ និងលើកទឹកចិត្តឱ្យស្ត្រីបានបង្ហាញនូវសក្ដានុពលរបស់ខ្លួនថាគាត់ក៏ជាធនធានមួយដ៏មានសារៈសំខាន់ដែលសង្គមជាតិ ត្រូវការចាំបាច់ដែរ ។
- កូតានេះគឺជាការលើកទឹកចិត្តឱ្យស្ត្រីបានចូលរួមដោយពេញលេញ ដោយស្មើភាព និងដោយសកម្មក្នុងការងារនយោបាយ ក៏ដូចជាការងារសាធារណៈ ដែលនឹង នាំមកនូវការផ្លាស់ប្ដូរនូវទម្លាប់នៃការអនុវត្តនយោបាយ ដើម្បីដោះស្រាយ និងសេចក្ដីត្រូវការរបស់ស្ត្រីនិងកុមារ ។ ការបង្កើនឱ្យមាននូវតម្លាភាព និងការទទួលខុសត្រូវរួមបញ្ចូលទាំងការឆ្លើយយ៉ាងរហ័សទៅនឹងសេចក្ដីត្រូវការ និងការទាមទាររបស់ប្រជាពលរដ្ឋមានសារៈសំខាន់ណាស់ក្នុងការពង្រឹងអភិបាលកិច្ចល្អ ដែលទាំងនេះគឺជាលក្ខខណ្ឌចាំបាច់សំរាប់ពន្លឿនសមភាព និងសមធម៌យេនឌ័រនៅកម្ពុជា ។

## ៧២. តើត្រូវធ្វើដូចម្ដេច ដើម្បីឱ្យប្រព័ន្ធកូតាសំរាប់តំណាងអ្នកបោះឆ្នោតអនុវត្តមានប្រសិទ្ធភាពនៅកម្ពុជា ?

- ត្រូវកំណត់កូតាយេនឌ័រនៅក្នុងច្បាប់បោះឆ្នោត ឬគោលនយោបាយរបស់គណបក្ស ឬពាក្យសាមញ្ញថា **កំណត់ចំនួនសមាមាត្រ** សំរាប់ស្ត្រីជាតំណាងអ្នកបោះឆ្នោតនៅកម្ពុជា យ៉ាងតិច ៣0% ជាការល្អ ។
- ច្បាប់ និងគោលនយោបាយទាំងនោះ ក៏ត្រូវបង្ខំគណបក្សនយោបាយបំពេញលក្ខខណ្ឌក្នុងការដាក់បេក្ខជនឈរឈ្មោះឆ្លាស់គ្នាបុរស-ស្ត្រីនៅក្នុងបញ្ជីឈរឈ្មោះខាងលើ យ៉ាងហោច ៣0% ។ បើបេក្ខជនជាបុរសឈរឈ្មោះនៅលេខរៀងទី១ ត្រូវដាក់បេក្ខជនជាស្ត្រី ឈរឈ្មោះនៅលេខរៀងទី២ ។ បើបេក្ខជនជាស្ត្រីឈរឈ្មោះ នៅលេខរៀង ទី១នោះត្រូវដាក់ បេក្ខជនជាបុរសឈរឈ្មោះនៅលេខរៀង

ទី២ វិញ ។

- ត្រូវលើកទឹកចិត្តស្ត្រីឈរឈ្មោះឱ្យបានច្រើន ហើយអ្នកបោះឆ្នោតត្រូវបោះឆ្នោតគាំទ្របញ្ជីបេក្ខជនណា ដែលបានដាក់បេក្ខជនបុរស-ស្ត្រីឆ្លាស់គ្នានៅបញ្ជីខាងលើ សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនាឆ្នាំ២០០៨ ខាងមុខនេះ ។

## ៧៣. ហេតុអ្វីបានជាស្ត្រីត្រូវចូលរួមក្នុងឆាកនយោបាយ និងជាអ្នកដឹកនាំ ?

- ស្ត្រីអាចអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ខ្លួន ក្នុងដំណើរការអភិវឌ្ឍន៍សង្គមជាតិ
- ដើម្បីឱ្យស្ត្រីមានឱកាសចូលរួមក្នុងតួនាទីធ្វើសេចក្តីសំរេចចិត្ត
- ធ្វើឱ្យមានការផ្លាស់ប្តូរស្ថានភាពស្ត្រី
- ដើម្បីចូលរួមក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ
- ដើម្បីលើកស្ទួយតំលៃស្ត្រី និងសមភាពយេនឌ័រ
- ដើម្បីបង្ហាញថាស្ត្រីក៏មានសមត្ថភាពដូចបុរសដែរ
- ដើម្បីកាត់បន្ថយទស្សនៈ *"ស្ត្រីភេទទន់ខ្សោយ"*
- ការពារផលប្រយោជន៍ស្ត្រីទាំងមូល
- ស្ត្រី និងបុរសមានសេចក្តីត្រូវការដោយឡែកៗពីគ្នា
- បើស្ត្រីមិនបានចូលរួម ស្ត្រីនៅតែមិនមានឱកាស ខ្វះបទពិសោធ និងមិនបានបង្កើនសមត្ថភាព
- ស្ត្រីត្រូវមានការយល់ដឹងពីនយោបាយ ដើម្បីអាចជួយតំរង់ទិសរួមគ្នា
- ស្ត្រីចូលរួមផ្តល់មតិ បំពេញភាពខ្វះចន្លោះ
- ស្ត្រីគ្រប់រូបមានសិទ្ធិចូលរួមក្នុងជីវភាពនយោបាយ
- ដើម្បីកែទំរង់នយោបាយ និងរចនាសម្ព័ន្ធច្បាប់របស់ជាតិ ដោយសន្តិវិធី
- ដើម្បីការពារសិទ្ធិស្ត្រី ដើម្បីអភិវឌ្ឍស្ត្រី ។

## ៧៤. តើឧបសគ្គអ្វីខ្លះដែលរារាំងស្ត្រីមិនឱ្យចូលរួមក្នុងវិស័យនយោបាយ ?

- ខ្វះចំណេះដឹង
- ខ្វះជំនាញ និងបទពិសោធ

- ខ្វះជំនឿលើខ្លួនឯង
- ជីវភាពគ្រួសារ
- ខ្វះការផ្តល់ឱកាស និងការគាំទ្រពីបុរស និងសង្គម
- ខ្វះការលើកទឹកចិត្តពីគ្រួសារ និងស្វាមី
- ឋានៈទាបក្នុងយន្តការធ្វើសេចក្តីសំរេចចិត្ត
- ការរើសអើងរវាងតួនាទីបុរស-ស្ត្រីក្នុងវិស័យការងារ
- ខ្វះគោលនយោបាយសមធមិសំរាប់ស្ត្រីនៅក្នុងច្បាប់បោះឆ្នោត និង គណបក្សនយោបាយ ។

## ៧៥. តើកត្តាអ្វីខ្លះ ដើម្បីលើកទឹកចិត្តស្ត្រី ឱ្យចូលរួមក្នុងកិច្ចការនយោបាយ ?

ក/ <u>កត្តាស្ត្រីខ្លួនឯង</u>

- បង្កើនសមត្ថភាព ចំណេះដឹង ភាពក្លាហានដោយខ្លួនឯង និងស្វែងយល់ពីសិទ្ធិរបស់ខ្លួន។
- គួរយល់ថា ការចូលរួមក្នុងកិច្ចការនយោបាយមិនមែនជាការប្រឈមនឹងគ្រោះថ្នាក់ទេ។ ដូចនេះគ្មានអ្វីដែលត្រូវព្រួយបារម្ភឡើយ ។
- កិច្ចការនយោបាយមិនមែនជាការបោកប្រាស់ ការកេងប្រវ័ញ្ច ការកៀបសង្កត់ពុករលួយទេ។

ខ/ <u>កត្តាសង្គម/នយោបាយ</u>

- ត្រូវទទួលស្គាល់ និងឱ្យតំលៃដល់សភាពជាធម្មជាតិរបស់ស្ត្រី (ការមានរដូវ ការមានគភ៌ ការសំរាលកូន)
- ផ្លាស់ប្តូរការឱ្យតំលៃរបស់សង្គម និងទំនៀមទម្លាប់ ប្រពៃណីទៅលើស្ត្រី ដូចជាទស្សនៈ *"ស្ត្រីបង្វិលចង្ក្រានមិនជុំ"* និង *"ស្ត្រីភេទទន់ខ្សោយ"* ជាដើម។
- ត្រូវយល់ដឹង និងផ្សព្វផ្សាយទាំងអស់គ្នាអំពីភាពស្មើគ្នារវាងបុរស និងស្ត្រីលើគ្រប់ទិដ្ឋភាពទាំងអស់ ។ សមត្ថភាពរបស់មនុស្ស មិនអាស្រ័យនឹងភេទជាបុរស ឬ ស្ត្រីឡើយ ។

- ត្រូវយល់ដឹងទាំងអស់គ្នាថាប្រាក់ខែ និងប្រាក់ចំណេញពីការរកស៊ីរបស់ប្តីមានតំលៃស្មើនឹងការងារផ្ទះរបស់ប្រពន្ធ ។
- បំបាត់អំពើហិង្សាលើស្ត្រីភេទ បង្កើតបណ្តាញ ឬចលនានយោបាយរបស់ស្ត្រី ។
- ផ្តល់ឱកាស និងមធ្យោបាយផ្សេងៗដល់ស្ត្រី ក្នុងការចូលរួមក្នុងវិស័យនយោបាយ និងកិច្ចការសង្គម...។
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីភាពជោគជ័យរបស់ស្ត្រីក្នុងការងារ,ការសិក្សា, ក្នុងថ្នាក់ដឹកនាំសម្រេចចិត្ត ។
- ត្រូវមានគោលនយោបាយសមធមិថ្នាក់ជាតិសំរាប់ផ្តល់ឱកាសដល់ស្ត្រីងាយស្រួលចូលរួមក្នុងនយោបាយ និងថ្នាក់សំរេចចិត្ត។
- អប់រំអ្នកបោះឆ្នោតឱ្យយល់ពីបញ្ហាស្ត្រី យល់ពីសារៈសំខាន់ស្ត្រីចូលរួមជាតំណាងអ្នកបោះឆ្នោតនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ។
- អ្នកបោះឆ្នោតត្រូវបោះឆ្នោតគាំទ្របញ្ជីបេក្ខជនណាដែលបានដាក់បេក្ខជនបុរស-ស្ត្រីឆ្លាស់គ្នានៅបញ្ជីខាងលើ គ្រប់ការបោះឆ្នោតទាំងអស់ ។
- បង្កើតកញ្ចប់ថវិកាជាតិដោយឡែកសំរាប់បណ្តុះបណ្តាលស្ត្រី ។

## ៧៦. តើនរណាជាអ្នកមើលឃើញបញ្ហារបស់ស្ត្រី ?

អ្នកដែលអាចមើលឃើញបញ្ហាស្ត្រី គឺមានតែស្ត្រីខ្លួនឯង ដូច្នេះហើយទើបគេ ទាមទារឱ្យស្ត្រីចូលរួមប្រឡូកក្នុងវិស័យនយោបាយ ឬក៏រិតដែលអាចធ្វើការសំរេចចិត្ត តាំងពីថ្នាក់ក្រុមប្រឹក្សាឃុំ-សង្កាត់រហូតដល់រដ្ឋសភា ព្រឹទ្ធសភា និងក្នុងរដ្ឋាភិបាលដើម្បីការពារផលប្រយោជន៍របស់ស្ត្រី និងចូលរួមដោះស្រាយបញ្ហាផ្សេងៗ ដែលធ្វើឱ្យមានការលំបាកដល់ស្ត្រី ដែលកើតចេញពីគោលនយោបាយរបស់រដ្ឋាភិបាល ដោយសារស្ត្រីជាជនដែលងាយរងគ្រោះ។

## ៧៧. តើការផ្តល់អំណាចដល់ស្ត្រីមានន័យដូចម្តេច ?

ការផ្តល់អំណាចឱ្យស្ត្រី គឺមានន័យថា ជាការបង្កើតឱកាសគ្រប់គ្រាន់លើជីវិតខ្លួនផ្ទាល់ វាមានន័យថា :

- អំណាចក្នុងការធ្វើសេចក្ដីសំរេច
- អំណាចក្នុងការធ្វើសំលេងមានប្រសិទ្ធភាព
- អំណាចក្នុងការបញ្ចូលគំនិតទៅក្នុងរបៀបវារៈ
- អំណាចក្នុងការចរចាស្ថានការណ៍ថ្មីៗ
- អំណាចផ្ទាល់ខ្លួនក្នុងការជំទាស់នឹងទំនៀមទម្លាប់ចាស់ៗ

# យុវជន និងនយោបាយ

## ៧៨. តើយុវជនចាំបាច់ចូលរួមក្នុងកិច្ចការនយោបាយដែរ ឬទេ? ព្រោះហេតុអ្វី?

យុវជនចាំបាច់ត្រូវតែចូលរួមក្នុងវិស័យនយោបាយ។ ព្រោះយុវជនក៏ដូចជាក្រុមមនុស្ស ដទៃទៀតដែរ ដែលមាន តម្រូវការផ្ទាល់ខ្លួន។ យុវជនជាប្រជាពលរដ្ឋដែលមានសិទ្ធិ និងកាតព្វកិច្ចចំពោះប្រទេសជាទូទៅ ដូចប្រជាពលរដ្ឋ គ្រប់វ័យដទៃទៀតដែរ។ អាចនិយាយបានថា ការចូលរួមនេះកាន់តែមានសារៈសំខាន់ជាងការចូលរួមរបស់ក្រុមប្រជាពល-រដ្ឋវ័យផ្សេងទៀត ដោយសារតែយុវជន ជាសរសរទ្រូងរបស់ជាតិ ជាកម្លាំងស្នូល ជាក្រុមមានមនសិការខ្ពស់ កម្លាំងកាយបរិបូរណ៍ និងមានកម្លាំងស្មារតី និងឆន្ទៈមុតមាំ។ ក្រុមយុវជនជា ក្រុមនៃអ្នកទើបនឹងចូលប្រឡូក ក្នុងការងារសង្គម ហេតុដូច្នេះ ពួកគេទំនងជាមានគំនិតសុទិដ្ឋិនិយមច្រើន មានទឹកចិត្តស្នេហាជាតិខ្ពស់ និងមានគំនិតច្នៃប្រឌិតថ្មីៗ ខុសពីអ្នកជំនាន់មុនៗ ដែលមានគំនិតអភិរក្សនិយមច្រើន។ ពួកគេមានតម្រូវការខុសពីអ្នកជំនាន់មុន ដោយសារពួកគេរស់នៅក្នុងសង្គមដែល ប្រែប្រួលវិវត្តន៍លឿន ជាពិសេសនាពេលបច្ចុប្បន្ននេះ។

ដូចនេះដើម្បីធានាឱ្យក្រុមរបស់ខ្លួន បានទទួលផលប្រយោជន៍ ឬមិនត្រូវបានគេផាត់ចោលពីការគ្រប់គ្រងប្រទេសយុវជនត្រូវតែចូលរួមក្នុងវិស័យនយោបាយ ដើម្បីឱ្យ អ្នកដឹកនាំមើលឃើញ ពីសក្ដានុពលរបស់ខ្លួន ក្នុងការធ្វើឱ្យមានការប្រែប្រួលក្នុងសង្គម នៅ

ពេលដែលតម្រូវការរបស់ខ្លួនមិនត្រូវបានគេពិនិត្យមើល និងដោះស្រាយ ។

ហេតុនេះការចូលរួមរបស់យុវជនក្នុងនយោបាយ នឹងធ្វើឱ្យក្រុមរបស់ខ្លួនមានសម្លេងនៅក្នុងសង្គម ជាពិសេសសម្រាប់ ប្រាប់ដល់ថ្នាក់ដឹកនាំ ហើយពេលនោះតម្រូវការរបស់ខ្លួននៅក្នុងសង្គមនឹងត្រូវបានគេយកចិត្តទុកដាក់ ។

## ៧៩. តើការចូលរួមរបស់យុវជនក្នុងកិច្ចការនយោបាយមានអ្វីខ្លះ?

រួមមាន:

- តាមដាន ស្វែងយល់ វិភាគ ព័ត៌មាន សភាពការណ៍សេដ្ឋកិច្ច សង្គម នយោបាយរបស់ប្រទេស និងចែករំលែក ផ្សព្វផ្សាយបន្តនូវព័ត៌មានណាដែលមានអត្ថប្រយោជន៍ដល់សង្គមជាតិ ។
- ខិតខំបង្កើនចំណេះដឹង និងកសាងសមត្ថភាពផ្ទាល់ខ្លួន ហើយចូលរួមសកម្មភាពនានា ក្នុងការស្ថាបនាសង្គម ដោយប្រកាន់យកមាគ៌ានយោបាយណាដែលស្អាតស្អំ ។
- មិនលុះតាមការទទួលយកផលប្រយោជន៍ ដែលបានពីនយោបាយទុច្ចរិតរបស់អ្នកដឹកនាំនយោបាយ ហើយនាំទុក្ខកង្វល់ដល់ប្រជាពលរដ្ឋខ្លួន ។
- ចូលរួមក្នុងការជ្រើសរើសតំណាងរបស់ខ្លួនដោយមានការពិចារណាឱ្យបានត្រឹមត្រូវតាមរយៈការបោះឆ្នោតដោយសំងាត់ និងមិនមែនចេះតែធ្វើការជ្រើសរើសដោយមិនបាន ពិចារណាថានរណាជាតំណាងរបស់ខ្លួនពិតប្រាកដនោះទេ ។
- តាមសង្កេតមើលការងាររបស់តំណាងខ្លួន និងការងាររាជរដ្ឋាភិបាល និងធ្វើការប្រជុំរវាងយុវជន ឬបង្កើតជា សមាគម ដោយបង្ហាញពីកង្វល់របស់ខ្លួនទាក់ទងនឹង ការងាររបស់រាជរដ្ឋាភិបាល
- ចូលរួមជាមួយគណបក្សនយោបាយដើម្បីមានឱកាសមានតួនាទីជាថ្នាក់ដឹកនាំក្នុងប្រទេស ឬជាតំណាងរាស្ត្រ នៅពេលអនាគត

## ៨០. តើការចូលរួមរបស់យុវជនក្នុងការបោះឆ្នោតមានសារៈសំខាន់ដែរឬទេ? ហេតុអ្វី?

ការចូលរួមរបស់យុវជនក្នុងការបោះឆ្នោតមានសារៈសំខាន់ណាស់ ។ ព្រោះនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នចំនួនប្រជាជនមានវ័យជាយុវជនមាន ប្រមាណ ៤លាននាក់មានន័យថាស្មើ នឹងប្រមាណពាក់កណ្តាលនៃចំនួនប្រជាជនមានសិទ្ធបោះឆ្នោត (ជាង៨លាននាក់) ។ ដូច្នេះការចូលរួមរបស់យុវជនក្នុងដំណើរការបោះឆ្នោតចាប់តាំងពីការចុះឈ្មោះរហូតដល់ពេលប្រកាសលទ្ធផល និងក្រោយពេលបោះឆ្នោតពិតជាអាចធ្វើឱ្យមានការប្រែប្រួលសង្គម ។ ដូច្នេះ គេអាចចាត់ទុកយុវជនជាកំលាំងចលករមួយយ៉ាងសំខាន់ដែលអាចជំរុញឱ្យប្រទេសជាតិរីកចំរើនបាន ។ ហេតុនេះ យុវជនត្រូវឈ្លាសវៃ ចេះប្រើប្រាស់សក្តានុពលរបស់ខ្លួនជំរុញឱ្យអ្នកនយោបាយបំរើដល់ផល ប្រយោជន៍ក្រុមខ្លួន និងប្រទេសជាតិទាំងមូល ។

## ៨១. តើយុវជនគួរធ្វើអ្វីខ្លះនៅក្នុងដំណើរការបោះឆ្នោត?

- **នៅដំណាក់កាលចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះ :** យុវជនត្រូវទៅចុះឈ្មោះបោះឆ្នោត បើខ្លួនមិនទាន់ចុះទេ ឈ្មោះបើចុះហើយ ត្រូវទៅពិនិត្យមើលឈ្មោះរបស់ខ្លួនថា តើមាននៅក្នុងបញ្ជីបោះឆ្នោត ឬទេ ។ ក្នុងករណីគ្មានឈ្មោះ ឬនៅលើឈ្មោះរបស់ខ្លួននោះ មានកំហុសត្រូវស្នើ សុំធ្វើការកែប្រែដើម្បីកុំឱ្យបាត់បង់សិទ្ធិបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។
- **នៅដំណាក់កាលចុះបញ្ជីគណបក្សនយោបាយ :** យុវជនត្រូវតាមដានថាតើគណបក្សនយោបាយណាខ្លះដែលប្រកួតប្រជែង ហើយត្រូវស្វះស្វែងរកព័ត៌មានទាក់ទងនឹងគណបក្សនយោបាយក៏ដូចជា ប្រវត្តិរបស់សមាជិកគណបក្សជាពិសេសបេក្ខជន ដែលឈរឈ្មោះនៅក្នុងមណ្ឌលរបស់ខ្លួន នៅក្នុងបញ្ជីគណបក្សនយោបាយ និងថ្នាក់ដឹកនាំគណបក្ស ដើម្បីជាទុនមួយសម្រាប់ធ្វើដែលខ្លួនពេញចិត្ត និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការឱ្យបានការសម្រេចចិត្តជ្រើសរើសបុគ្គលដែលជាតំណាងរបស់ខ្លួន ។
- **ការឃោសនា :** ត្រូវតាមអង្កេតមើលពីគោលនយោបាយរបស់គណបក្សនយោ

បាយ ក៏ដូចជាបេក្ខជនឈរឈ្មោះ ទីមួយៗថាតើវាមានផលប្រយោជន៍សម្រាប់យុវជនណា ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមឱ្យកាន់ តែសកម្មជនក្នុងដំណើរការបោះឆ្នោត ពួកគេអាចធ្វើការទាក់ទងនឹងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការសង្កេតដំណើរការបោះឆ្នោត ដើម្បីចុះឈ្មោះចូលរួមស្ម័គ្រចិត្តធ្វើជាអ្នកសង្កេតការណ៍បោះឆ្នោត ។ ម្យ៉ាងវិញទៀត យុវជនគ្រប់អាយុបោះឆ្នោតដែល កំពុងសិក្សានៅតាមវិទ្យាល័យ និងមហាវិទ្យាល័យក៏អាចរួមផ្តុំជាសមាគម ស្នើសុំប័ណ្ណសំគាល់អ្នកសង្កេតការណ៍ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ។

- **នៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត :** យុវជនត្រូវទៅបោះឆ្នោត ហើយពេលរាប់សន្លឹកឆ្នោតយុវជនត្រូវនៅ ចាំមើលលទ្ធផលដើម្បីធានាថា ការរាប់សន្លឹកឆ្នោតនោះគ្មានការបន្លំ ។
- **ថ្ងៃប្រកាសលទ្ធផលឆ្នោត:** យុវជនត្រូវពិនិត្យមើលថាតើបេក្ខជនដែលខ្លួនជ្រើសរើសនោះបានជាប់ដែរឬទេ? ។

## ៨២. តើក្រោយថ្ងៃបោះឆ្នោតយុវជនគួរធ្វើអ្វីទៀតដើម្បីឱ្យមានប្រយោជន៍ដល់សង្គម និង ខ្លួនឯងផ្ទាល់?

យុវជនត្រូវតាមដានមើលពីសកម្មភាពរបស់តំណាងរបស់ខ្លួន ក៏ដូចជាការងាររបស់រាជរដ្ឋាភិបាលដែលបានកើតឡើងចេញពីការបោះឆ្នោតមកនេះ ដើម្បីជាព័ត៌មានសម្រាប់ការសម្រេចចិត្តលើកក្រោយ ក្នុងការជ្រើសរើសតំណាងរបស់ខ្លួន។ ក្នុងករណីដែលការអនុវត្តរបស់មន្ត្រីជាប់ឆ្នោតមិនឆ្លើយតបទៅអ្វីដែលបានសន្យា ឬក្នុងគោលនយោបាយគណបក្សទាក់ទងនឹងយុវជន ហើយយុវជនត្រូវត្រៀមខ្លួនដើម្បីលើកឡើងពីកង្វល់របស់ខ្លួនដល់មន្ត្រីជាប់ឆ្នោត។ យុវជនអាចពិចារណាសាជាថ្មីសំរាប់ការបោះឆ្នោតលើកក្រោយៗទៀត។

## ៨៣. តើយុវជនគួរធ្វើយ៉ាងណា ដើម្បីឱ្យមានការគិតគូខ្ពស់ពីអ្នកកាន់អំណាចលើបញ្ហារបស់យុវជន?

ដំបូងយុវជនត្រូវបង្ហាញថា ខ្លួនគឺជាអ្នកដែលមានសក្តានុពលក្នុងការធ្វើឱ្យសម្លេង

ឆ្នោត មានការប្រែប្រួល ។យុវជនខ្មែរ ដែលមានអាយុពី ១៨-៣០ ឆ្នាំ មាន ជាង៤លាននាក់ ឬជាង៥០% នៃអ្នកមានសិទ្ធិបោះឆ្នោតជាយុវជន ដូចនេះវាបញ្ជាក់យ៉ាងច្បាស់ថា យុវជនជាអ្នកបោះឆ្នោតដ៏គួរឱ្យចាប់អារម្មណ៍របស់គណបក្សនយោបាយ ។ តែអ្វីដែលសំខាន់នោះគឺយុវជនត្រូវធ្វើយ៉ាងណាឱ្យមានសម្លេងរួមដើម្បីផលប្រយោជន៍រួមរបស់ពួកគេ ។ ជាមួយគ្នានេះ យុវជនក៏ត្រូវបង្ហាញដល់ថ្នាក់ដឹកនាំដែរថា ខ្លួនមានឥទ្ធិពលទៅលើក្រុមមនុស្សដទៃទៀត ដូចជា មនុស្សជំទង់ ឬមនុស្សចាស់ ព្រោះខ្លួន គឺជាយុវជនដែលមាន ចំណេះដឹង និងកាយសម្បទាល្អ ហើយអាចធ្វើការអប់រំ និងជួយដល់មនុស្សដទៃទៀត ។ ដូចនេះ សម្ដីរបស់យុវជននឹងអាចធ្វើឱ្យមានការប្រែប្រួលដល់ការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំ ។ ចុងបញ្ចប់ យុវជនខ្លួនឯងផ្ទាល់ត្រូវព្យាយាម ចូលរួមក្នុងការគ្រប់គ្រងប្រទេស ឬត្រូវក្លាយជាតំណាងរាស្ត្រ ដើម្បីជួយដោះស្រាយបញ្ហារបស់ក្រុមខ្លួន ។

## ៨៤. តើយុវជនគួរធ្វើយ៉ាងណាដើម្បីឱ្យខ្លួនមានតំលៃក្នុងសង្គម ?

ទោះមានចំណេះដឹងជ្រៅជ្រះ តិចតួច ឬមិនមានក្ដី យុវជនត្រូវតែធ្វើអត្តចរិតឱ្យបានសមជាពលរដ្ឋល្អ ។ ជាមួយគ្នានេះ យុវជនត្រូវតែព្យាយាមធ្វើការតាមដានរាល់ការដឹកនាំរបស់អ្នកនយោបាយ ហើយត្រូវចេះលើកយកបញ្ហាដែលធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍប្រទេសជាតិមកធ្វើការជជែកពិភាក្សាជាមួយអ្នកនយោបាយតាមគ្រប់មធ្យោបាយដូចជា ចូលរួមក្នុងវេទិកានានាដែលរៀបចំឡើងដោយអង្គការសង្គមស៊ីវិល គណបក្សនយោបាយ និងរដ្ឋាភិបាលជាដើម ។



# ឈ្លាសវៃ! ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៨




**បោះឆ្នោតដើម្បីកាត់បន្ថយភាពក្រីក្រ ដោះស្រាយបញ្ហា និងអនាគតពួកយើង**

## ផលិតដោយ

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា**

**Committee for Free and Fair Elections in Cambodia**

គាំទ្រពី
Supported By

ឧបត្ថម្ភថវិកាដោយ
Funded By

From
the People of Japan


**អាសយដ្ឋាន / Address**

ស្នាក់ការ : ផ្ទះលេខ១៣៨ ផ្លូវលេខ ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
P.O.Box 1145, CCC Box 439,
Phone : (023) 884 150 / 012 942 019 / 012 942 017, Fax : (855-23) 883 750
Phnom Penh, E-mail : comfrel@online.com.kh, Website: http://www.comfrel.org